**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# កិច្ចសន្យាខ្ចីបរិភោគ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **នៅ ទី**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ឧត្តី**


ថ្នាក់ **បរិញ្ញាបត្រនីតិសាស្ត្រ**

ជំនាញ **នីតិសាស្ត្រ** ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# អារម្ភកថា

ដោយសារពីមួយថ្ងៃទៅមួយថ្ងៃការរីកចម្រើននៃសេដ្ឋកិច្ចមានការផ្លាស់ប្តូរជាលំដាប់ តែងតែមានការអភិវឌ្ឍន៍នូវអ្វីដែលថ្មីៗជាពិសេសជីវភាពរស់នៅរបស់ប្រជាជន យ៉ាងណាមិញការអភិវឌ្ឍន៍គឺតែងតែមានការជះឥទ្ធិពលទៅលើកត្តាជីវភាពរបស់មនុស្ស ដោយយើងសង្កេតឃើញថាតុល្យភាពនៃកម្រិតជីវភាពរបស់ពួកគាត់មិនទាន់មានភាពល្អប្រសើរទាំងអស់នោះឡើយ ដូច្នេះទើបសកម្មភាពមួយចំនួនដូចជា៖ ការលក់-ដូរ ការបញ្ចាំ ការជួល ការខ្ចីបរិភោគ និងសកម្មភាពច្រើនទៀតមានការវិវត្តន៍ថ្មីទៅតាមបរិបទនៃសម័យកាល។ ដោយឡែកក្នុងនោះ គេបានចាប់អារម្មណ៍ឃើញមានសកម្មភាពមួយប្រភេទដែលតែងតែកើតមានឡើងជាញឹកញ៉ាប់ នៅក្នុងសកម្មភាពរស់នៅនោះគឺ សកម្មភាពនៃការខ្ចីបរិភោគ។ ក្នុងការសិក្សាស្រាវជ្រាវបង្កើតនូវអ្វីដែលថ្មី អ្វីដែលជាគុណប្រយោជន៍សម្រាប់មនុស្សជាតិនាពេលបច្ចុប្បន្ន និង អនាគត។ ហើយយោងតាមតម្រូវការជាក់ស្តែងនៃកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ ក្នុងនាម ខ្ញុំបាទជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការបង្កើត សារណាស្រាវជ្រាវ នេះឡើងក្នុងគោលបំណងចែករំលែកនូវចំណេះដឹងដែលបានសិក្សាកន្លងរួចមកក្នុង ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ហើយជាពិសេសគឺដើម្បីបង្ហាញពីសមត្ថភាព និងលទ្ធភាពនៃការយល់ដឹងទាក់ទងទៅនឹងប្រធានបទ "**កិច្ចសន្យាខ្ចីបរិភោគ**"។

តាមរយៈប្រធានបទដ៏មានសារៈសំខាន់ខាងលើ ខ្ញុំបាទសង្ឃឹមថាសារណាមួយនេះ ពិតជាអាចផ្តល់ចំណេះដឹងមួយផ្នែកដល់ បណ្តាអ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិតដែលចង់ស្វែងយល់ ឬចង់សិក្សាស៊ីជម្រៅស្តីអំពី **កិច្ចសន្យាខ្ចីបរិភោគ** និងជាមាគ៌ាសម្រាប់បណ្តាអ្នកសិក្សាស្រាវជ្រាវ និងសិស្ស និស្សិត ជំនាន់ក្រោយបន្តធ្វើការសិក្សាបន្ថែមទៀត។

ជាទីបញ្ចប់ខ្ញុំបាទ សូមធ្វើការអភ័យទោសទុកជាមុន នូវរាល់កំហុសខុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនា តាមរយៈកំហុសអក្ខរាវិរុទ្ធ ការបកស្រាយ និងប្រើប្រាស់ពាក្យពេចន៍មិនសមស្របដោយប្រការណាមួយ ក៏ដូចជាកង្វះខាតអត្ថន័យក្តី។ ជាពិសេសខ្ញុំបាទសង្ឃឹមថា នឹងទទួលបានការយោគយល់ អធ្យាស្រ័យ ហើយក៏រង់ចាំទទួលរាល់ការកែលម្អពីសំណាក់ សាស្ត្រាចារ្យ សិស្សនិស្សិត មិត្តៗអ្នកអាន ដោយក្តីសោមនស្សរីករាយ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **នៅ ឌី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ ថ្នាក់ L3A10នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា ២០១៧- ២០២១។

**សូមធ្វើគារវកិច្ច និង កតញ្ញូតាធម៌ចំពោះ**

- លោកឪពុក **នៅ ចំរើន** និងអ្នកម្តាយ **ម៉ន់ ចាន្នី** ដែលលោកអ្នកមានគុណយ៉ាងធំធេង មិនអាចកាត់ថ្លៃបានចំពោះរូបកូនដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សារូបកូនប្រកបដោយព្រហ្មវិហារធម៌ និងបានបញ្ជូនកូនឲ្យទៅ សាលារៀនទទួលការសិក្សារៀនសូត្រ ក្រេបជញ្ជក់យកចំណេះដឹង ដើម្បីរស់នៅដោយកិត្តិយស សេចក្តីថ្លៃថ្នូរ ចេះបែងចែកអ្វីជាទង្វើល្អ និងឈរលើជំហររឹងមាំ ព្រមទាំងតែងតែគ្រើនលំរឹកជារឿយៗឱ្យកូនចេះតស៊ូជំនះគ្រប់ឧបសគ្គដោយសេចក្តីក្លាហានក្នុងជីវិត។
- ឯកឧត្តម **លុយ ចន្ណា** សាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់។

ជាពិសេសលោកសាស្ត្រាចារ្យ **ញឹក ឧុឌ្ឋី** ជាសាស្ត្រាចារ្យណែនាំ របស់ខ្ញុំបាទក្នុងសារណានៃការស្រាវជ្រាវ ដែលលោកបានជួយជ្រោមជ្រែង និងចំណាយពេលដ៏មានតម្លៃក្នុងការត្រួតពិនិត្យ និងផ្តល់ការពិភាក្សាជាប់ជាប្រចាំ។ មិនត្រឹមតែប៉ុណ្ណោះ លោកសាស្ត្រាចារ្យ ថែមទាំងជួយយ៉ាងពេញទំហឹងក្នុងការបង្ហាត់បង្រៀនទូន្មានប្រៀនប្រដៅ បង្ហាញទិសដៅ និងផ្តល់ជាអនុសាសន៍ល្អៗ ពន្យល់ណែនាំខ្ញុំបាទ អស់ពីកម្លាំងកាយចិត្ត អស់ពីសមត្ថភាព មិនគិតអំពីការនឿយហត់ក្នុងការអប់រំគ្រប់បែបយ៉ាងមិនថាចំណេះដឹង និងសីលធម៌។ គុណូបការៈដ៏ថ្លៃថ្លាទាំងនេះធ្វើឲ្យខ្ញុំបាទដឹងគុណ និងចងចាំជានិច្ចមិនអាចបំភ្លេចបាន និងសូមប្រសិទ្ធពរជ័យសេរីសួរស្តី សូមលោកសាស្ត្រាចារ្យ និងក្រុមគ្រួសារបានជួបប្រទះតែ គុណបុណ្យព្រះរតនត្រ័យ ដែលជាវត្ថុស័ក្កសិទ្ធិក្នុងលោកមាន ពុទ្ធរតនៈ ធម្មរតនៈ និងសង្ឃរតនៈ ជាទីពឹងគ្រប់ពេលវេលា ព្រមទាំងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងចៀសឆ្ងាយពីជំងឺដ៏កាចសាវ កូវីដ១៩។ ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតអំពីខ្ញុំ ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

៣.គោលបំណងនៃការស្រាវជ្រាវ ........ ១

៤.វិសាលភាពនៃការសិក្សាស្រាវជ្រាវ ........ ២

៥.សារៈសំខាន់នៃការស្រាវជ្រាវ ........ ២

៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ២

**ជំពូកទី ១៖ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាខ្ចីបរិភោគ**

**១.១. សមត្ថភាព** ........ ៣

**១.១.១.សមត្ថភាពទទួលបាននូវសិទ្ធិ** ........ ៣

**១.១.២.សមត្ថភាពខាងឆន្ទៈ** ........ ៤

**១.១.៣.សមត្ថភាពក្នុងការធ្វើសកម្មភាព** ........ ៤

**១.២.ការព្រមព្រៀង** ........ ៤

**១.២.១.ការព្រមព្រៀងដោយពិតប្រាកដ** ........ ៥

១.២.១.១.សំណើ ........ ៥

១.២.២.២.ស្វីការ ........ ៧

**១.២.២.ការព្រមព្រៀងដោយសេរី** ........ ៨

១.២.២.១.ការព្រមព្រៀងមិនត្រូវឱ្យមានវិការៈ ........ ៨

**១.៣. កម្មវត្ថុ** ........ ១៣

**១.៣.១.កម្មវត្ថុនៃកិច្ចសន្យា** ........ ១៣

**១.៣.២.កម្មវត្ថុនៃកាតព្វកិច្ច** ........ ១៣

**ជំពូកទី២៖ កិច្ចសន្យាខ្ចីបរិភោគ**

**២.១.និយមន័យ** ........ ១៥

**២.២.ប្រភេទនៃកិច្ចសន្យាខ្ចីបរិភោគ** ........ ១៥

**២.៣.លក្ខខណ្ឌចាំបាច់នៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគ** ........ ១៦

**២.៤.ការប្រាក់** ........ ១៧

**២.៤.១.អត្រានៃការប្រាក់** ........ ១៧

២.៤.១.១.អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ........ ១៧

២.៤.១.២.កម្រិតនៃអត្រាការប្រាក់ ........ ១៨

២.៤.១.៣.អត្រាការប្រាក់ក្នុងកិច្ចសន្យា ........ ១៨

**២.៤.២. ការការពារអ្នកខ្ចី** ........ ១៩

**២.៤.២.ការប្រាក់សមាស** ........ ២០

**២.៤.៣.ពេលវេលានៃការបង់ប្រាក់** ........ ២០

## ជំពូកទី៣៖ អានុភាពនៃកិច្ចសន្យាខ្ចីបរិភោគ

**៣.១.សិទ្ធិ និងភាតព្វកិច្ចរបស់គូភាគី** ........ ២១

**៣.១.១.សិទ្ធិ និងភាតព្វកិច្ចរបស់ភាគីអ្នកឲ្យខ្ចី** ........ ២១

៣.១.១.១.ករណីយឱ្យខ្ចីវត្ថុដែលជាកម្មវត្ថុ ........ ២១

៣.១.១.២.ការទទួលខុសត្រូវក្នុងការធានារបស់ភាគីអ្នកឱ្យខ្ចី ........ ២២

៣.១.១.៣.ករណីដែលអ្នកខ្ចីបានប្រគល់វត្ថុដែលជារបស់អ្នកដទៃ ........ ២២

៣.១.១.៤.ករណីវត្ថុមានវិការៈ ........ ២៤

៣.១.១.៥.ការទាមទារឱ្យសងមកវិញក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីបានធ្លាក់ចុះ ... ២៥

**៣.១.២. សិទ្ធ និងភាតព្វកិច្ចរបស់អ្នកខ្ចី** ........ ២៦

៣.១.២.១.ករណីយកិច្ចសងនូវវត្ថុ ........ ២៦

៣.១.២.២.ពេលវេលានៃការសង ........ ២៧

៣.១.២.៣.ទីកន្លែងនៃការសង ........ ២៩

៣.១.២.៤.ករណីដែលអ្នកខ្ចីមិនអាចសងនូវវត្ថុបាន ........ ២៩

៣.១.២.៥.កាតព្វកិច្ចនៃការបង់ការប្រាក់ ........ ៣០

**សេចក្តីសន្និដ្ឋាន** ........ ៣១

**អនុសាសន៍**........................................................................................................................................ ៣៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ដោយយោងតាមយោងតាមទិដ្ឋភាពជាក់ស្តែងនៅក្នុងសង្គម បានឃើញថាបុគ្គលម្នាក់ៗខិតខំប្រឹងប្រែងប្រកបមុខរបរ បង្កើតជាជំនួញជួញដូរ សម្រាប់ទ្រទ្រង់ជីវភាពគ្រួសាររបស់ខ្លួនជាប្រចាំ។ ដោយកាលៈទេសៈខ្លះជួបនូវការលំបាកខ្វះខាតខាងផ្នែកសម្ភារៈ ឬក៏ជួបការខ្វះខាតខាងសេដ្ឋកិច្ច ទើបតម្រូវឱ្យមានការខ្ចីគ្នាទៅវិញទៅមក ដើម្បីបំពេញតម្រូវការចាំបាច់ជាប្រយោជន៍រៀងៗខ្លួន។ អាស្រ័យដូចការរៀបរាប់ខាងលើនេះ គេឃើញមានការកើតឡើងនូវវិវាទជាច្រើររវាងអ្នកឱ្យខ្ចី និងអ្នកខ្ចីដែលបណ្តាលមកពីការមិនដឹងច្បាស់លាស់អំពីការខ្ចីបរិភោគនោះ ទើបបង្កើតជាការឈ្លោះទាស់ទែងគ្នារហូតដល់មានការប្តឹងប្តល់គ្នាជាហូរហែរ។ ទន្ទឹមនឹងនេះផងដែរ ដើម្បីកុំឱ្យមានការប្តឹងផ្តល់គ្នាដែលជាហេតុនាំឱ្យមានការខូចខាត់ដល់ប្រយោជន៍រវាងភាគីទាំសងខាងនោះ ភាគីទាំងអស់គួរគប្បីធ្វើការសិក្សារស្វែងយល់អំពីរបៀបនៃការបង្កើតនូវកិច្ចសន្យានេះ និងមើលទៅលើលក្ខខណ្ឌដែលត្រូវមាននៅក្នុងកិច្ចសន្យា។ ហើយនីតិវិធីនៃការបង្កើត ព្រមទាំងលក្ខខណ្ឌនោះត្រូវតែស្របតាមគោលការណ៍ក្រមរដ្ឋប្បវេណីដែលបានបញ្ញត្តិ និងច្បាប់ផ្សេងៗដែលមានការពាក់ព័ន្ធដែលបានតាក់តែងឡើងនិងបានចុះជាធរមាន។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

តើអ្វីទៅជាការខ្ចីបរិភោគ? តើការខ្ចីបរិភោគត្រូវបង្កើតឡើងនៅពេលណា? តើភាគីនៃការខ្ចីបរិភោគ មានសិទ្ធិ និងករណីយកិច្ចអ្វីខ្លះ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

កម្មវត្ថុនៃការសិក្សារស្រាវជ្រាវទៅប្រធានបទមួយនេះគឺ ស្វែងយល់អំពី សិទ្ធ និងករណីយកិច្ចរវាងអ្នកឲ្យខ្ចីបរិភោគ និងអ្នកទទួលខ្ចីបរិភោគដែលមាននៅក្នុងកិច្ចសន្យាខ្ចីបរិភោគ។ មិនត្រឹមតែប៉ុណ្ណោះ ចង់ចែករំលែកនូវចំណេះដឹង បន្ទាប់ពីបានធ្វើការសិក្សាជាច្រើនឆ្នាំកន្លងមក ទៅដល់មិត្តអ្នកអាន និងនិស្សិតជំនាន់ក្រោយៗទៀតផងដែរ។

## ៤.វិសាលភាពនៃការសិក្សាស្រាវជ្រាវ

ប្រធានបទនៃការសិក្សាមួយនេះ គឺមានទំនាក់ទំនងទៅនឹងសិទ្ធិបុគ្គលឯកជន នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានចែងក្នុងមាត្រា ៥៧៨ ដល់មាត្រា ៥៩៥ នៃក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដែលចូលជាធរមាន។ អាស្រ័យហេតុនេះហើយយើងខ្ញុំសូមធ្វើការសិក្សាស្រាវជ្រាវដោយលើកយកត្រឹមតែមាត្រាដែលមានកំណត់ ដូចខាងលើមកធ្វើជាសម្អាងក្នុងការបកស្រាយ។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺចង់បង្ហាញទៅដល់អ្នកសិក្សាគ្រប់គ្នា បានយល់ដឹងឱ្យកាន់តែស៊ីជម្រៅទៅលើ កិច្ចសន្យាខ្ចីបរិភោគ ទុកជាឯកសារសម្រាប់អានដើម្បីជាចំណេះដឹង និងជាឯកសារសម្រាប់ស្រាវជ្រាវ។ ពោលគឺ ជាដំបូងដែលមានសារៈសំខាន់ជាងគេនោះ ត្រូវតែគោរពតាមលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាទូទៅសិន មុននឹងឈានដល់ការគោរពតាមគោលការណ៍របស់កិច្ចសន្យាខ្ចីបរិភោគ ដើម្បីទទួលបាននូវកិច្ចសន្យាខ្ចីបរិភោគមួយដែលមានភាពពេញលេញតាមផ្លូវច្បាប់។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដោយផ្អែកតាមរយៈលទ្ធផលនៃការស្រាវជ្រាវសារណានេះ យើងនឹងសិក្សាទៅលើ ៣ ជំពូកគឺ៖

- **ជំពូកទី១៖ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាកិច្ចខ្ចីបរិភោគ**
- **ជំពូកទី២៖ កិច្ចសន្យាខ្ចីបរិភោគ**
- **ជំពូកទី៣៖ អានុភាពនៃកិច្ចសន្យាខ្ចីបរិភោគ**

ដូច្នេះយើងខ្ញុំនឹងសូមធ្វើការសិក្សាទៅលើ ជំពូកនីមួយៗទាំង៣ខាងលើនេះ ដោយបង្ហាញជូនទាំងស្រុងនៅក្នុងសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំដូចខាងក្រោមនេះតទៅ។

# ជំពូកទី ១៖ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាខ្ចីបរិភោគ

កិច្ចសន្យាខ្ចីបរិភោគ ត្រូវបង្កើតឡើងដោយការព្រមព្រៀងរវាងអ្នកឱ្យខ្ចី និងអ្នកខ្ចីតែប៉ុណ្ណោះ[1]។ ដោយយោងតាមខ្លឹមសារនៃមាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណីខាងលើនេះ គឺយើងអាចបានថាការបង្កើតកិច្ចសន្យាខ្ចីបរិភោគត្រូវធ្វើឡើង ដោយបុគ្គលពីរនាក់ដែលមានសមត្ថភាពតាមផ្លូវច្បាប់ ធ្វើការព្រមព្រៀងគ្នា និងមានកម្មវត្ថុមួយជាក់លាក់ ក្នុងការបង្កើតកិច្ចសន្យាមួយដែលលាយល័ក្ខណ៍អក្សរ។

បើយោងទៅតាមនិយមន័យនៃកិច្ចសន្យាទូទៅ គឺកិច្ចសន្យាមានន័យថាជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់ មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច។ កិច្ចសន្យាជាប្រភពនៃការបង្កើតឱ្យមានកាតព្វកិច្ច ដែលជាចំណងគតិយុត្តចងបុគ្គលពីរនាក់ ដោយបុគ្គលម្នាក់ដែលបានកំណត់ មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។

សុពលភាពរបស់កិច្ចសន្យាដែលអាចយកជាការបានលុះត្រាតែកិច្ចសន្យានោះ កើតចេញពីជនដែលមានសមត្ថភាពចុះកិច្ចសន្យា ធ្វើការព្រមព្រៀងដោយពិតប្រាកដ និងដោយសេរី ហើយមានកម្មវត្ថុជាក់លាក់ ដែលអាចកើតឡើង ស្របច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ល្អ។

## ១.១. សមត្ថភាព

### ១.១.១.សមត្ថភាពទទួលបាននូវសិទ្ធិ

រូបវន្តបុគ្គលគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច[2]។ ការទទួលបានសិទ្ធិ គឺមានចំពោះរូបវន្តបុគ្គលទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជា ដោយឡែកចំពោះជនជាតិបរទេសមិនអាចទទួលនូវការកាន់កាប់សិទ្ធមួយចំនួនដែលច្បាប់ និងបញ្ញត្តិផ្សេងៗបានកំណត់។ សមត្ថភាពរបស់រូបវន្តបុគ្គល និងនីតិបុគ្គលដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ប្រសិនបើភាគីណាម្ខាងនៃកិច្ចសន្យាមិនមានសមត្ថភាពទទួលសិទ្ធិទេ កិច្ចសន្យានោះនឹងគ្មានសុពលភាព។

[1] មាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[2] មាត្រា ៦ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ១.១.២.សមត្ថភាពខាងឆន្ទៈ

សមត្ថភាពខាងឆន្ទៈ គឺជាសកម្មភាពរបស់ភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនអាចយល់ដឹង និងវិនិច្ឆ័យបាននូវលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ ច្បាប់ក៏មានការកំណត់អំពីការខ្វះសមត្ថភាពខាងឆន្ទៈផងដែរ ដូចជាជនដែលខ្វះសមត្ថភាពនៃការយល់ដឹង និងមិនអាចធ្វើការវិនិច្ឆ័យខាងផ្លូវច្បាប់ចំពោះសកម្មភាពរបស់ខ្លួន ដែលបណ្ដាលមកពីបញ្ហាបញ្ញាស្មារតី។

### ១.១.៣.សមត្ថភាពក្នុងការធ្វើសកម្មភាព

សមត្ថភាពក្នុងការធ្វើសកម្មភា គឺសំដៅទៅលើសមត្ថភាពរបស់បុគ្គលដែលអាចបង្ហាញឆន្ទៈប្រកបដោយប្រសិទ្ធិភាព និងដោយឯករាជ្យមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់នរណា។ បុគ្គលដែលមានសមត្ថភាពពេញលេញអាចធ្វើការបង្ហាញឆន្ទៈប្រកបដោយសុពលភាព ហើយធ្វើការសម្រេចចិត្តដោយផ្ទាល់ខ្លួនបានដែលមិនចាំបាច់មានការជួយពីបុគ្គលផ្សេងទៀត។ ជនដែលត្រូវបានកម្រិតសមត្ថភាព ត្រូវបានការអនុញ្ញាតពីអ្នកមានអំណាចមេបា អាណាព្យាបាល ឬហិតូបត្ថម្ភកៈរបស់ជននោះ នៅមុនពេលបង្ហាញឆន្ទៈរបស់ខ្លួន។ ប៉ុន្តែក្នុងករណីជននោះមិនបានទទួលបានការអនុញ្ញាតពីអ្នកមានអំណាចមេបា អាណាព្យាបាល ឬហិតូបត្ថម្ភកៈនោះទេ រាល់សកម្មភាពដែលបានធ្វើទាំងនោះអាចលុបចោលបាន។ អនីតិជនដែលមានអាយុក្រោម ១៨ឆ្នាំ ដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងជនដែលនៅក្រោមហិតូបត្ថម្ភ គឺជាជនដែលច្បាប់បានកម្រិតសមត្ថភាព។ ក្នុងករណីដែលច្បាប់បានធ្វើការលើកលែង លុះត្រាតែអនីតិជនអាយុក្រោម១៨ឆ្នាំនោះទទួលបានអត្តាធិនភាព គឺអនីតិជននោះអាចមានសមត្ថភាពក្នុងការធ្វើសកម្មភាពបាន។

## ១.២.ការព្រមព្រៀង

ការព្រមព្រៀង ជាធាតុសំខាន់មួយនៅក្នុងការបង្កើតកិច្ចសន្យា។ ហើយជាគោលការណ៍វាមានអនុភាពនៅពេលដែលសំណើរ និងស្ទីការត្រូវបានជួបគ្នា។

## ១.២.១.ការព្រមព្រៀងដោយពិតប្រាកដ

### ១.២.១.១.សំណើ

សំណើ គឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយឆន្ទៈភ្ជាប់ជាមួយនឹងចំណងគតិក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ[3]។

អនុភាពនៃសំណើនឹងកើតមានឡើងនូវពេលដែលសំណើនោះ បានទៅដល់ភាគីម្ខាងទៀត។ សំណើដែលបានទៅទីដល់លំនៅស្ថានរបស់ភាគីម្ខាងទៀតគឺ គេចាត់ទុកថាភាគីម្ខាងទៀតបានទទួលសំណើនោះ មួយវិញទៀត ប្រសិនបើអ្នករស់នៅជាមួយបានទទួលសំណើនោះជំនួសក៏គេចាត់ទុកថាសំណើរនោះត្រូវបានទទួលដែរ។

**ក.លក្ខខណ្ឌសុពលភាព**

**● សំណើត្រូវបញ្ជាក់ពីគោលបំណងពិតប្រាកដ**

សំណើត្រូវបង្ហាញឱ្យច្បាស់ថា អ្នកធ្វើសំណើមានគោលបំណងចង់ធ្វើកិច្ចសន្យាយ៉ាងពិតប្រាកដមែន។ សំណើដែលអ្នកស្នើ ធ្វើឡើងដោយមិនបានបង្ហាញអំពីគោលបំណងប្រកដប្រជាក្នុងការធ្វើកិច្ចសន្យា នោះវាគ្មានសំណើតាមផ្លូវច្បាប់សំរាប់ភាគីម្ខាងទៀតធ្វើស្ទីការឡើយ។ ដូច្នេះវាក៏មិនអាចបង្កើតកិច្ចសន្យាមួយដែលចងកាតព្វកិច្ចរវាងភាគីទាំងសងខាងបានដែរ។

**ឧទាហរណ៍៖** លោក **ក** បានធ្វើសំណើទៅកាន់លោក **ខ** ដែលលោក **ក** មានគោលបំណងខ្ចីស្រូវ លោក **ខ** ដើម្បីសាបព្រោះ។

**● សំណើត្រូវច្បាស់លាស់**

ដើម្បីឱ្យសំណើមួយទៅជាសំណើមួយដែលច្បាស់លាស់ពេញលេញគ្រប់គ្រាន់ទៅបាន លុះត្រាតែសំណើនោះ ត្រូវតែបង្ហាញឱ្យច្បាស់លាស់ពីខ្លឹមសារ គោលបំណងពិតប្រាកដ និងត្រូវធ្វើជាលាយល័ក្ខអក្សរ។

**ឧទាហរណ៍៖** លោក **ក** បានដាក់សំណើជាលិខិតដែលមានលាយល័ក្ខអក្សរទៅកាន់លោក **ខ** ថាគាត់សុំខ្ចីលុយចំនួន ១០០ដុល្លា ដោយបញ្ជាក់ថាគាត់នឹងសងវិញនៅ ២០ថ្ងៃក្រោយ។ ហើយ

[3] មាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

លោក **ខ** បានទទួលសំណើ និងព្រមទទួលយកសំណើរនោះដោយឱ្យលោក **ក** ខ្ចីប្រាក់នោះចំនួន ១០០ដុល្លា។ ដូច្នេះសំណើនោះបានបញ្ជាក់ថា លោក **ក** មានគោកបំណងខ្ចីប្រាក់ពីលោក **ខ** ។

- **ដំណឹងនៃសំណើត្រូវឱ្យដឹងដល់អ្នកទទួលសំណើ**

ប្រសិនបើអ្នកស្នើរមិនបានធ្វើសំណើរបស់ខ្លួនដឹងដល់ភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតមិនបានទទួលសំណើក៏មិនអាចបង្កើតកិច្ចសន្យាដែលជាប់កាតព្វកិច្ចជាមួយអ្នកស្នើនោះទេ។

ប៉ុន្តែករណីដែលអ្នកស្នើ ឬអ្នកទទួលសំណើអាចប្រគល់សិទ្ធិអំណាចរបស់ខ្លួនទៅអ្នកផ្សេងដើម្បីធ្វើសំណើ ឬអ្នកទទួលសំណើជំនួសឱ្យខ្លួនបាន។

សំណើមានអនុភាពនៅពេលដែលសំណើនោះបានទៅដល់ភាគីម្ខាងទៀត[4]។

**ខ.អនុភាពនៃសំណើ**

- **សំណើមានកំណត់អំឡុងពេលសម្រាប់ស្វីការ និងការដកសំណើ**

សំណើមានកំណត់អំឡុងពេលសម្រាប់ស្វីការ ជាសំណើមួយដែលភាគីម្ខាងដែលអ្នកស្នើបានដាក់សំណើរបស់ខ្លួន ទៅភាគីម្ខាងទៀតដែលជាអ្នកទទួលសំណើ និងបានបញ្ជាក់ច្បាស់លាស់អំពីពេលវេលា។

សំណើដែលកំណត់ថេរៈវេលាគឺ អ្នកធ្វើសំណើត្រូវរក្សាទុកនូវថេរៈវេលា ដើម្បីបញ្ជាក់ថា អ្នកធ្វើសំណើមិនអាចដកសំណើបានមុនរយៈពេលនៃការធ្វើស្វីការ។

សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្វីការ។ អំឡុងពេលសំរាប់ធ្វើស្វីការត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ បើមិនច្បាស់ថាអ្នកស្នើកំណត់ពេលផ្សេង។

សំណើដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសំរាប់ស្វីការ មិនអាចដកវិញបានទេ។

ប្រសិនបើអ្នកស្នើ មិនបានទទួលដំណឹងអំពីស្វីការក្នុងអំឡុងពេលផុតដែលបានកំណត់នៅចំណុចទី១ ខាងលើនេះទេ សំណើនោះត្រូវបាត់បង់អានុភាពដោស្វ័យប្រវត្តិនៅពេលផុតអំឡុងពេល

[4] មាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

សម្រាប់ស្វីការ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានដល់អ្នកសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសំរាប់ធ្វើស្វីការនោះ សំណើនោះក៏ត្រូវបាត់បង់អនុភាពដែរ[5]។

**• សំណើគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និងការដកសំណើ**

សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ ជាសំណើមួយដែលភាគីម្ខាងដែលជាអ្នកស្នើបានដាក់សំណើរបស់ខ្លួន ទៅភាគីម្ខាងទៀតដែលជាអ្នកទទួលសំណើដោយមិនបានបញ្ជាក់ពីថេរៈវេលាសម្រាប់ធ្វើស្វីការ។ សំណើមិនបានកំណត់ថេរៈវេលា អ្នកធ្វើសំណើត្រូវរក្សាក្នុងរយៈពេលសមស្រប ហើយអាស្រ័យទៅតាមទំលាប់នៃការប្រើប្រាស់។

ចំពោះសំណើដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេល សម្រាប់ស្វីការរវាងគូភាគីដែលកំពុងនិយាយគ្នានៅក្នុងស្ថានភាពដែលអាចធ្វើភ្លាមៗបាន ប្រសិនបើភាគដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព។

ចំពោះសំណើដែលធ្វើរវាងគូភាគីដែលមិននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ។

ការដកសំណើត្រូវមានអានុភាព នៅពេលដែលការជូនដំណឹងអំពីការដកសំណើនោះ បានមកដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្វីការ[6]។

### ១.២.២.២.ស្វីការ

ស្វីការ គឺជាអំពើក្នុងការបង្ហាញឆន្ទៈនៃការព្រមព្រៀងចំពោះសំណើណាមួយដោយច្បាស់លាស់ ជាលាយល័ក្ខអក្សរ ឬផ្ទាល់មាត់។

ស្វីការ ជាការបង្ហាញឆន្ទៈ ដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ[7]។ សំណើមិនអាចមានលក្ខខណ្ឌលើស ឬបន្ថែម កែប្រែផ្សេងៗទៅលើសំណើនៅពេលដែលស្វីការត្រូវបានឆ្លើយតបទៅលើសំណើដើមបានឡើយ។

ករណីដែលអាចកែប្រែសំណើបានលុះត្រាតែ៖

[5] មាត្រា ៣៣៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[6] មាត្រា ៣៣៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[7] មាត្រា ៣៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- ក្នុងករណីដែលអ្នកធ្វើស្ទីការបានដាក់សក្ខខណ្ឌលើសំណើ ឬការកែប្រែសារធាតុផ្សេងៗនៃសំណើមិនត្រូវក្លាយជាស្ទីការសុពល តែស្ទីការនោះមានអនុភាពជាសំណើថ្មី។ កិច្ចសន្យាដែលត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើមធ្វើស្ទីការចំពោះសំណើថ្មីនោះ។
- ប្រសិនបើលក្ខខណ្ឌ ឬការកែប្រែដែលភ្ជាប់ជាមួយនឹងស្ទីការមិនធ្វើឱ្យមានការកែប្រែសារធាតុនៃសំណើទេ ស្ទីការនោះមានសុពលភាព លុះត្រាតែអ្នកស្នើមិនអាចតវ៉ាភ្លាម។ អត្ថន័យនៃកិច្ចសន្យាដែលត្រូវកើតឡើងដោយស្ទីការនោះ ត្រូវទៅតាមអត្ថន័យនៃស្ទីការលុះត្រាតែអ្នកស្នើដែលទទួលស្ទីការមិនតវ៉ាភ្លាមៗទេ [8]។

**ឧទាហរណ៍៖** លោក **ក** បានដាក់សំណើទៅលោក **ខ** សុំខ្ចីប្រាក់ពីលោក **ខ** ចំនួន ១០០ដុល្លា ហើយបញ្ជាក់ថាគាត់នឹងសងលោក **ខ** ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០២១ ដោយសារលោក **ក** ជាគាត់ត្រូវបើកប្រាក់បៀវត្ស៍នៅថ្ងៃនោះ។ ប៉ុន្តែលោក **ខ** បានយល់ព្រមឱ្យខ្ចី តែត្រូវសងនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០២១។ ដូច្នេះស្ទីការមានអនុភាពជាសំណើថ្មី។ ករណីនេះប្រសិនបើលោក **ក** មិនធ្វើការតវ៉ាភ្លាមៗទេនោះបានន័យថាគាត់យល់ព្រមនឹងសំណើថ្មីរបស់លោក **ខ** ហើយសំណើថ្មីនោះមានអនុភាព។

### ១.២.២.ការព្រមព្រៀងដោយសេរី

#### ១.២.២.១.ការព្រមព្រៀងមិនត្រូវឱ្យមានវិការៈ

ការព្រមព្រៀង អាចចាត់ទុកថាមានប្រសិទ្ធិភាពគតិយុត្តបានលុះត្រាតែការព្រមព្រៀងនោះបានសំដែងឡើងចេញពីឆន្ទៈដោយសេរី និងដោយបានដឹងអំពីហេតុផលសព្វគ្រប់។

កិច្ចសន្យា គឺមិនត្រូវមានវិការៈនោះទេ ពីព្រោះបើមានវិការៈគឺកិច្ចសន្យានោះនឹងមិនមានអនុភាពគតិយុត្តឡើយ។ វិការៈនៃកិច្ចសន្យាមានដូចខាងក្រោមនេះ៖

[8] មាត្រា ៣៤២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ក.ការភាន់ច្រឡំ**

ការភាន់ច្រឡំ គឺសំដៅទៅលើការមិនដឹងរបស់គាគីក្នុងការបង្ហាញឆន្ទៈ។ គ្រប់ករណីនៃការភាន់ច្រឡំ គឺមិនបណ្តាលឱ្យមានវិការៈនៃការព្រមព្រៀងទាំងអស់នោះទេ ហើយច្បាប់ក៏មិនងាយទទួលស្គាល់នូវមោឃភាពដែលបណ្តាលមកពីការភាន់ច្រឡំដោយងាយស្រួលបានដែរ។

ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗ នៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ភាគីដែលបានយល់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬចំណុចដែលភាគីយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យាទោះបី ជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

ការលុបចោលនូវការបង្ហាញឆន្ទៈដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែប្រសិនបើតតិយជនសុចរិត ហើយគ្មានកំហុសអំពីការភានច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជនោះបានឡើយ[9]។

**ខ.ការឆបោក**

បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យាដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ។ ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុ

[9] មាត្រា ៣៤៦ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ថាការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះបានដឹង ឬអាចដឹងអំពីការឆបោកនោះ។

ការលុបចោលនូវកិច្ចសន្យាដោយការឆបោកក្រៅពីភាគីម្ខាងទៀត អាចអះអាងបានចំពោះតតិយជនបាន។ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអះអាងនូវអានុភាពនៃការលុបចោលនៃការលុបចោលចំពោះតតិយជននោះបានឡើយ [10]។

ខ្លឹមសារខាងនេះចង់បញ្ជាក់ថា អ្នកបង្ហាញឆន្ទៈមានសិទ្ធិលុបចោលកិច្ចសន្យាបានប្រសិនបើការបង្ហាញឆន្ទៈនោះត្រូវបានធ្វើឡើងដោយមានការឆបោកដោយភាគីម្ខាងទៀត ឬតតិយជន។ ប៉ុន្តែ បើការបង្ហាញឆន្ទៈខុសពីឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដោយសារការឆបោក ហើយកិច្ចសន្យានោះត្រូវបានបង្កើតរួចទៀត ទោះបីជាអ្នកបង្ហាញឆន្ទៈត្រូវបានបន្ទោសថាឱ្យគេបោកក៏ដោយក៏ត្រូវតែការពារអ្នកដែលបង្ហាញឆន្ទៈនោះដែរ។

**ឧទាហរណ៍៖** បុគ្គលិករបស់ហាងលក់ឡានម៉ាក **ក** បានបញ្ចុះបញ្ចូលអតិថិជនឱ្យជឿនូវអង្គហេតុថា ឡាននេះជាផលិតផលរបស់ក្រុមហ៊ុន **ខ** ដែលឡានកំពុងពេញនិយម ទាំងដឹងថាការពិតឡាននេះគឺជាផលិតផលរបស់ក្រុមហ៊ុន **គ** ហើយអតិថិជនក៏ជឿ និងបានទិញឡាននោះ។ ដូចនេះអតិថិជនអាចលុបចោល កិច្ចសន្យាដោយផ្អែកលើការឆបោកបាន។

ក្នុងករណីដែលការបង្ហាញឆន្ទៈនោះត្រូវធ្វើឡើងដោយការឆបោករបស់ភាគីម្ខាងទៀត វាមិនមានអ្វីកើតឡើងទេ ប្រសិនបើការលុបចោលត្រូវបានអនុញ្ញាត ព្រោះគេមិនចាំបាច់ការពារភាគីម្ខាងទៀតឡើយ។ ចំណែកឯករណីដែលតតិយជនមានសុចរិតភាព ដោយមិនមានកំហុសអំពីការឆបោកនោះទេ មិនអាចអះអាងអានុភាពនៃការលុបចោលចំពោះតតិយជនបានឡើយ។

### គ.ព័ត៌មានមិនពិត

នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ដោយហេតុថាការបង្ហាញឆន្ទៈនោះជាការពិត ប៉ុន្តែ

[10] មាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

**ឧទាហរណ៍៖** ហាងលក់ម៉ូតូ **ក** បានយល់ច្រឡំថា ម៉ូតូប្រភេទម៉ូតូចិន ថាជាម៉ូតូដែលជាផលិផលរបស់ជប៉ុន ហើយក៏បានទិញយកមកលក់ដោយដាក់ផ្លាកម៉ូតូជប៉ុន។ ដោយអតិថិជនបានជឿជាក់ថាដែលដាក់លក់មានផ្លាកម៉ូតូជប៉ុននោះ ក៏បានទិញម៉ូតូនោះ។ ដូច្នេះ ក្នុងករណីនេះប្រសិនបើអតិថិជនបានដឹងថាម៉ូតូនោះជាប្រភេទម៉ូតូចិន គាត់មិនទិញទេ ហេតុនេះអតិថិជនដែលបានទិញម៉ូតូនោះអាចលុបចោលកិច្ចសន្យាបាន ដោយផ្អែកលើព័ត៌មានមិនពិត។

ប៉ុន្តែចំណុចនេះមិនរារាំងដល់ភាគីដែលបានបង្ហាញឆន្ទៈ ក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញឆន្ទៈមិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស។

ការលុបចោលនូវកិច្ចសន្យា ដោយព័ត៌មានមិនពិតក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ[11]។

ចំណុចនៃការបង្ហាញឆន្ទៈដែលធ្វើឡើងដោយព័ត៌មានមិនពិត គឺស្រដៀងគ្នាទៅនឹងការឆបោកដែរ ប៉ុន្តែការឆបោកកើតឡើងតែក្នុងករណីដែលអ្នកផ្តល់ព័ត៌មានមិនពិតមានចេតនាប៉ុណ្ណោះ។ ចំណែកឯព័ត៌មានមិនពិត ទោះបីជាអ្នកបង្ហាញព័ត៌មានមិនពិតនោះគ្មានចេតនា ឬគ្មានកំហុសក៏ដោយ ក៏កើតមានឡើងដែរ។ មានករណីជាច្រើនដែលព័ត៌មានមិនពិត និងការឆបោកកើតឡើងទាំងពីរ ចំពោះករណីបែបនេះ អ្នកបង្ហាញឆន្ទៈអាចលើកយកទាំងពីរ មកអះអាងបាន។

### ឃ.ការរំលោភលើស្ថានភាព

នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម ឬបានប្រើស្ថានភាពផ្សេងទៀតដែលគូភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទី ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

[11] មាត្រា ៣៤៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការលុបចោលនូវកិច្ចសន្យាដោយយោងតាមចំណុចខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាព [12]។

**ឧទាហរណ៍៖** លោក **ក** បានសុំខ្ចីរថយន្តដឹកទំនិញពីលោក **ខ** រយៈពេល៥ថ្ងៃ។ ប្រសិនបើលោក **ខ** មិនឱ្យខ្ចីនោះទេគាត់នឹងបណ្តេញកូនរបស់លោក **ក** មិនឱ្យធ្វើការនៅក្រុមហ៊ុនរបស់គាត់។

**ខ.ការគម្រាមកំហែង**

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ [13]។

**ឧទាហរណ៍៖** លោក **ក** បានប្រាប់ទៅលោក **ខ** ថា បើមិនចង់ស្លាប់ទេ គឺត្រូវតែចុះកិច្ចសន្យាឱ្យខ្លួនខ្ចីដី ដើម្បីធ្វើអាជីវកម្មរបស់ខ្លួន។ ដោយសារការភ័យខ្លាច លោក **ខ** ក៏បានយល់ព្រមក្នុងការចុះកិច្ចសន្យាឱ្យលោក **ក** ខ្ចីដី។ ក្នុងករណីនេះលោក ខ អាចលុបចោលកិច្ចសន្យាដោយផ្អែកលើការគម្រាមកំហែងបាន។

**ច.អំពើកេងយកចំណេញហួសហេតុ**

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ ឬការខ្វះការពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ[14]។

**ឧទាហរណ៍៖** លោក **ក** បានទៅខ្ចីលុយពីលោក **ខ** ដើម្បីយកមកមើលកូនឈឺ។ លោក **ខ** ក៏បានឱ្យលុយទៅលោក **ក** ខ្ចីចំនួន ២លានរៀល ដោយគិតការប្រាក់ចំនួន ១៩ភាគរយក្នុងមួយឆ្នាំ។

[12] មាត្រា ៣៤៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[13] មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[14] មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ឆ.ឋបនីយផ្លូវចិត្ត**

ឋបនីយផ្លូវចិត្ត គឺជាការបង្ហាញឆន្ទៈខាងក្រៅដែលមានអត្ថន័យខុសពីឆន្ទៈពិត ទាំងដឹងថាឆន្ទៈដែលបានបង្ហាញនោះខុសពីឆន្ទៈពិត។

ប្រសិនបើ កិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងថាខុសឆន្ទៈរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថា ការបង្ហាញនោះខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន។

**១.៣. កម្មវត្ថុ**

**១.៣.១.កម្មវត្ថុនៃកិច្ចសន្យា**

កម្មវត្ថុនៃកិច្ចសន្យា គឺជាវត្ថុ ប្រាក់ ឬសេវា ដែលអាចអនុវត្ត និងប្រតិបត្តិបាន។ វត្ថុនៅក្នុងកិច្ចសន្យាគឺត្រូវតែជាវត្ថុមួយដែលជាក់លាក់ (អាចកំណត់បាន) ដែលធ្វើទៅកើត និងស្របច្បាប់ របៀបរាបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ[15]។ ដូច្នេះកម្មវត្ថុនៃកិច្ចសន្យាមិនមានភាពផ្ទុយនឹងច្បាប់ និងធ្វើឱ្យប៉ះពាល់ដល់របៀបរាបរយសាធារណៈ និងប្រពៃណីល្អនោះឡើយ បើពុំនោះទេកិច្ចសន្យាដែលបង្កើតនោះនឹងត្រូវមោឃភាពមិនដាក់ឱ្យអនុវត្តឡើយ។

**១.៣.២.កម្មវត្ថុនៃកាតព្វកិច្ច**

កម្មវត្ថុនៃកាតព្វកិច្ច ជាការផ្តល់នូវតាវកាលិក ឬរបស់អ្វីមួយដែលគូភាគីត្រូវតែផ្តល់ឱ្យគ្នាទៅវិញទៅមក ដូចជាការបង់ការប្រាក់ចំពោះចំពោះកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់។

**ឧទាហរណ៍៖** លោក **ក** បានខ្ចីប្រាក់ពី លោក **ខ** ដោយការខ្ចីបរិភោគមានភ្ជាប់ការប្រាក់។ ដូចនេះលោក **ក** ត្រូវបង់ការប្រាក់ឱ្យលោក **ខ** ទៅតាមលក្ខខណ្ឌនៃការបង់ដែលបានព្រមព្រៀងគ្នានោះ។

កិច្ចសន្យាទាំងឡាយណាដែលយកជាបានការបានលុះត្រាតែកាតព្វកិច្ចដែលកើតអំពីកិច្ចសន្យានោះមានកម្មវត្ថុមួយដែលជាក់លាក់ ដែលអាចធ្វើទៅកើត និងដែលស្របច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ។

[15] មាត្រា៣ នៃក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា

កម្មវត្ថុដែលជាក់លាក់ គឺជាវត្ថុដែលត្រូវតែកំណត់ ឬអាចកំណត់បាន មានន័យថាភាគីក្នុងកិច្ចសន្យាមានលទ្ធភាពវាស់ ឬស្ទង់នូវទំហំកាតព្វកិច្ចរបស់ខ្លួនបាន។

វត្ថុដែលអាចធ្វើទៅកើត គឺជាកម្មវត្ថុនៃកិច្ចសន្យាដែលមនុស្សទូទៅអាចធ្វើកើត ប្រសិនបើកម្មវត្ថុនៃកិច្ចសន្យានោះមិនអាចធ្វើកើតទេ គឺបណ្តាលឱ្យកិច្ចសន្យាមោឃៈភាព។ ភាពមិនអាចធ្វើកើតដែលធ្វើឱ្យកិច្ចសន្យារងមោឃៈភាព គេត្រូវពិនិត្យមើលទៅលើ ភាពអាចធ្វើកើត ឬមិនអាចធ្វើកើត ថាវាមានលក្ខខណៈដាច់ខាតដែរ ឬទេ បើវាមានលក្ខណៈដាច់ខាតនោះកិច្ចសន្យានឹងត្រូវមោឃៈភាព ផ្ទុយទៅបើមានលក្ខខណៈមិនដាច់ខាតទេកិច្ចសន្យានោះនៅមានសុពលភាព។

កម្មវត្ថុស្របច្បាប់ របៀបរាបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ បានន័យថាកម្មវត្ថុនៃកិច្ចសន្យាដែលស្របច្បាប់ មិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ ទាល់តែកម្មវត្ថុនៃកិច្ចសន្យាស្ថិតក្នុងពាណិជ្ជកម្ម។ កម្មវត្ថុដែលមិនស្របច្បាប់ ដូចជា៖

- វត្ថុទាំងឡាយដែលជាទ្រព្យសម្បត្តិរបស់សាធារណៈរដ្ឋ
- កិរិយារបស់ភាគីដែលជាការប្រព្រឹត្តអំពើអ្វីមួយដែលច្បាប់បានហាមឃាត់។

វត្ថុមួយចំនួនទៀតដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ដូចជា អាវុធ គ្រឿងញៀន គ្រឿងផ្ទុះជាដើម មិនអាចជាកម្មវត្ថុនៃកិច្ចសន្យាបានឡើយ។ សរីរាង្គមនុស្ស ក៏មិនអាចក្លាយជាកម្មវត្ថុនៃកិច្ចសន្យាបានដែរ តែបើករណីដែលកិច្ចសន្យានោះធ្វើអំណោយដោយស្ម័គ្រចិត្តរបស់ភាគីនោះគឺអាចធ្វើបាន។

# ជំពូកទី២៖ កិច្ចសន្យាខ្ចីបរិភោគ

## ២.១.និយមន័យ

ការខ្ចីបរិភោគ គឺសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ឬវត្ថុជំនួសផ្សេងទៀតកំឡុងពេលដែលមានកំណត់ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ។[16]

កិច្ចសន្យាខ្ចីបរិភោគ គឺជាប្រភេទនៃកិច្ចសន្យាទ្វេភាគីមួយបង្កើតឡើងដោយបុគ្គលចាប់ពីពីរនាក់ដែលមានកម្មវត្ថុជាក់លាក់មួយ ហើយភាគីទាំងសងខាងមានកាតព្វកិច្ចបំពេញឲ្យគ្នាទៅវិញទៅមក បានន័យថាភាគីម្ខាងដែលជាអ្នកឲ្យខ្ចីមានករណីកិច្ចប្រគល់នូវប្រាក់ ឬវត្ថុ ឲ្យទៅភាគីម្ខាងទៀតដែលជាអ្នកខ្ចី នៅក្នុងពេលវេលាដែលបានកំណត់ជាក់លាក់ណាមួយ។ ចំណែកឯភាគីដែលជាអ្នកខ្ចីវិញត្រូវមានកាតព្វកិច្ចប្រគល់ប្រាក់ ឬវត្ថុដែលមានគុណភាព ប្រភេទ និងបរិមាណស្មើនឹងប្រាក់ ឬវត្ថុដែលអ្នកឲ្យខ្ចីបានប្រគល់ឲ្យខ្លួននោះ តាមការកំណត់ដោយមានការព្រមព្រៀងគ្នា នៅក្នុងកិច្ចសន្យា។

**ឧទាហរណ៍៖** អ្នកខ្ចីបានខ្ចី អង្ករ ហើយអ្នកខ្ចី មានសេរីភាពក្នុងការប្រើប្រាស់អង្ករនោះបាន ហើយអ្នកខ្ចី មានករណីយកិច្ចសងទៅឱ្យអ្នកខ្ចីវិញនូវអង្ករដែលមាន ប្រភេទ គុណភាព និងបរិមាណដូចគ្នា ក្រោយពីអំឡុងពេលកំណត់សងបានកន្លងផុតទៅ។

## ២.២.ប្រភេទនៃកិច្ចសន្យាខ្ចីបរិភោគ

កិច្ចសន្យាខ្ចីបរិភោគត្រូវបានបែងចែកជា២ប្រភេទ៖

### ក.កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ គឺជាកិច្ចសន្យាខ្ចីបរិភោគដែលយកតម្លៃថ្នូរ បានន័យថាភាគីអាចបង្កើតកិច្ចសន្យាដោយយកការប្រាក់ ចំពោះការបរិភោគដែលការប្រាក់នេះត្រូវតែ

[16] មាត្រា ៥៧៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ធ្វើជាលិខិតលាយលក្ខណ៍អក្សរដោយ និងត្រូវមានការចុះហត្ថលេខារបស់ភាគី ទើបការបរិភោគនោះមានអានុភាពចំពោះសិទ្ធិលើបំណុលនៃការប្រាក់។

**ខ.កិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់**

កិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់ គឺជាកិច្ចសន្យាបរិភោគដែលមិនយកតម្លៃថ្នូរ ភាគីអាចមិនធ្វើជាលិខិតដែលលាយលក្ខណ៍អក្សរក៏បានប៉ុន្តែវាជាបញ្ហាសំរាប់ភាគីអ្នកខ្ចី ដោយសារតែភាគីអ្នកឱ្យខ្ចីអាចមានសិទ្ធិក្នុងការដកហូតនូវវត្ថុ ឬទ្រព្យនោះពេលណាក៏បាន។

## ២.៣.លក្ខខណ្ឌចាំបាច់នៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

កិច្ចសន្យាខ្ចីបរិភោគត្រូវបង្កើតឡើង ដោយការព្រមព្រៀងគ្នារវាងភាគីអ្នកឱ្យខ្ចី និងអ្នកខ្ចីតែប៉ុណ្ណោះ[17]។ កិច្ចសន្យាខ្ចីបរិភោគ ជាកិច្ចសន្យាដែលបង្កើតឡើងដោយការព្រមព្រៀងគ្នារវាងគូភាគីនៃកិច្ចសន្យា ដូច្នេះការបង្កើតកិច្ចសន្យានេះត្រូវបង្កើតតាមលក្ខខណ្ឌគ្រឹះ។ ភាគីក៏អាចបង្កើតកិច្ចសន្យាដែលមានកម្មវត្ថុជាការសងការប្រាក់ តាមការព្រមព្រៀងបាន។

ការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ មិនមានអានុភាពឡើយក្នុងករណីដែលពុំបានធ្វើតាមលិខិតជាលាយលក្ខអក្សរដោយមានចុះហត្ថលេខារបស់អ្នកខ្ចី [18] ។ ភាគីអាចបង្កើតកិច្ចសន្យាខ្ចីបរិភោគ ដោយមិនចាំបាច់កំណត់រយៈពេលក្នុងការសងបាន ប៉ុន្តែអ្វីដែលចាំបាច់ចំពោះការកំណត់វិញនោះ គឺកំណត់ពី គុណភាព ចំនួន និងប្រភេទនៃវត្ថុដើម្បីបង្កើតកិច្ចសន្យាខ្ចីបរិភោគ។ វត្ថុដែលបានកំណត់ជាក់លាក់ ដូចជាអចលនវត្ថុមិនអាចធ្វើជាកម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគបានឡើយ ពីព្រោះ វាមិនអាចជំនួសបាន។

តាមគោលការណ៍សេរីភាពនៅក្នុងការបង្កើតកិច្ចសន្យា ភាគីអាចធ្វើការកំណត់អានុភាពនៃកិច្ចសន្យានឹងកើតមានឡើង ក្នុងពេលដែលមានការធ្វើលិខិតនៃកិច្ចសន្យាកនោះជាលាយលក្ខណ៍អក្សរ ឬក្នុងពេលដែលភាគីអ្នកឱ្យខ្ចីប្រគល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យានោះទៅឱ្យភាគីអ្នកខ្ចី។

[17] មាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[18] មាត្រា ៥៧៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ២.៤.ការប្រាក់

ការប្រាក់ សំដៅទៅលើចំនួនទឹកប្រាក់ ឬវត្ថុផ្សេងទៀតដែលត្រូវបានផ្តល់ទៅឱ្យតាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ ក្នុងនាមជាតម្លៃតបចំពោះការប្រើប្រាស់ ឬវត្ថុដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ ឬវត្ថុដែលខ្ចី មកធ្វើជាមេគុណនឹងអត្រាការប្រាក់ដែលត្រូវបានកំណត់[19]។ ការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់នេះ គឺភាគីនៃកិច្ចសន្យាអាចធ្វើការព្រមព្រៀងគ្នាចំពោះការប្រាក់ក្នុងការកំណត់។

**ឧទាហរណ៍៖** លោក **ក** បានខ្ចីប្រាក់ពីលោក **ខ** ចំនួន ១០០ដុល្លា ជាមួយនឹងការប្រាក់ ៣ភាគរយក្នុងមួយខែ។ ដូច្នេះនៅពេលដែលបង់ការប្រាក់ គឺត្រូវយក ១០០ x ០,០៣ = ៣០ដុល្លា។

### ២.៤.១.អត្រានៃការប្រាក់

អត្រាការប្រាក់ត្រូវបានបែងចែកចេញត្រូវបានបែកចែកជា៣ប្រភេទ៖

- អត្រាការប្រាក់ដែលកំណត់ដោយច្បាប់
- អត្រាការប្រាក់ដែលត្រូវបានកម្រិត
- និងអត្រាការប្រាក់នៅក្នុងកិច្ចសន្យា[20]។

#### ២.៤.១.១.អត្រាការប្រាក់ដែលកំណត់ដោយច្បាប់

ការខ្ចីបរិភោគដែលមិនមានការកំណត់អត្រាការប្រាក់ទេនោះ អត្រាការប្រាក់ដែលត្រូវកំណត់យកតាមក្រមរដ្ឋប្បវេណី ដែលអត្រាការប្រាក់នោះត្រូវបានកំណត់ក្នុងក្រមរដ្ឋប្បវេណី។ ចំពោះកាតព្វកិច្ចដែលត្រូវបង្កើតការប្រាក់ ក្នុងករណីដែលគ្មានការកំណត់ផ្សេងទេត្រូវគិតអត្រាការប្រាក់ចំនួន ៥ភាគរយក្នុងមួយឆ្នាំ [21]។

ប្រសិន គូភាគីបានព្រមព្រៀងគ្នាបង់ការប្រាក់ ប៉ុន្តែមិនបានកំណត់អំពីការប្រាក់ទេនោះ អត្រាការប្រាក់ដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ពិសេស ត្រូវយកមកអនុវត្ត[22]។

---

[19] មាត្រា ៥៨៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[20] មាត្រា ៥៨៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[21] មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[22] មាត្រា ៥៨៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការកំណត់ដោយក្រមរដ្ឋប្បវេណី គឺបើកចំហឱ្យគូភាគីមានការព្រមព្រៀងគ្នាតាមឆន្ទៈរបស់ខ្លួន ប៉ុន្តែការព្រមព្រៀងកំណត់នោះត្រូវតែស្ថិតនៅក្រោមការប្រាក់ដែលច្បាប់បានកម្រិត។

**២.៤.១.២.កម្រិតនៃអត្រាការប្រាក់**

អត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលត្រូវបានកំណត់ក្នុងកថាខណ្ឌទី១នៃមាត្រា៥៨៥ នៃក្រមរដ្ឋប្បវេណី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រឹមអត្រាការប្រាក់ចាប់ពី ១០ភាគរយទៅ ៣០ភាគរយក្នុងមួយឆ្នាំ[23]។

ដោយសារតែការកម្រិតបែបនេះ មានការជះឥទ្ធិពលដល់ភាគីអ្នកខ្ចី និងស្ថានភាពជាក់ស្តែងអំពីកម្រិតជីវភាពរបស់ប្រជាជន។ ដូច្នេះក្រសួងយុត្តិធម៌ក៏បានធ្វើការសម្រេចកំណត់យកនូវអត្រាការប្រាក់ដែលមិនលើសពីចំនួន ១៨ភាគរយ ក្នុងមួយឆ្នាំឡើយ [24]។ ហើយការកំណត់បែបនេះ គឺក្នុងគោលបំណងក្នុងការពារផលប្រយោជន៍របស់ភាគីអ្នកខ្ចីដើម្បីកុំឱ្យមានការប្រើប្រាស់ឆន្ទៈច្រើនលើសលប់ក្នុងការកំណត់អត្រាការប្រាក់ពីសំណាក់ភាគីអ្នកឱ្យខ្ចី។

**២.៤.១.៣.អត្រាការប្រាក់ក្នុងកិច្ចសន្យា**

អាត្រាការប្រាក់នៅក្នុងកិច្ចសន្យា គឺសំដៅទៅលើការព្រមព្រៀងគ្នារវាងគូភាគីនៃកិច្ចសន្យាក្នុងការកំណត់អាត្រាការប្រាក់ហើយចែងវានៅក្នុងកិច្ចសន្យានោះបាន។ ការកំណត់អាត្រាការប្រាក់ដែលកំណត់ដោយតាមការព្រមព្រៀងនៅក្នុងកិច្ចសន្យា គឺជាការផ្តល់នូវសិទ្ធិបុគ្គលឯកជនដល់គូភាគី។

ទន្ទឹមនឹងគ្នានេះផងដែរ អាត្រាការប្រាក់នៅក្នុងកិច្ចសន្យាអាចលើស ឬខ្ពស់ជាអាត្រាការប្រាក់ដែលកំណត់ដោយច្បាប់ តែមិនត្រូវខ្ពស់ជាងអាត្រាការប្រាក់ដែលច្បាប់បានកម្រិតនោះទេ[25]។ ចំពោះករណីដែលអ្នកខ្ចីបានសងប្រាក់ ទៅឱ្យរួចរាល់ ក្នុងចំនួនដែលលើសពីការប្រាក់ដែលបានកម្រិត ការប្រាក់នោះនឹងត្រូវចាត់ទុកជាបំណុលទៅលើប្រាក់ដើម។

[23] មាត្រា ១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

[24] ប្រការ ១ នៃប្រកាសស្តីពីអាត្រាការប្រាក់ដែលត្រូវបានកម្រិត

[25] មាត្រា ៥៨៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ២.៤.២. ការការពារអ្នកខ្ចី

នៅក្នុងករណីនៃការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ អ្នកឱ្យខ្ចី ដូចជា អ្នកឱ្យខ្ចីដែលមានគោលបំណងអាក្រក់ តែងតែព្យាយាមគេចវេសពីច្បាប់ ទោះបីជាច្បាប់បានបញ្ញត្តិនូវការកម្រិតលើការប្រាក់ក៏ដោយ។ ដូចនេះ ក្រមរដ្ឋប្បវេណីបានចែងនូវបញ្ញត្តិចំនួនពីរ ដើម្បីធ្វើការការពារអ្នកខ្ចី។

**ក.ការកែប្រែប្រាក់ដើម**

ក្នុងករណីដែលចំនួនទឹកប្រាក់ដើមលើកិច្ចសន្យា ខុសគ្នាពីចំនួនទឹកប្រាក់នៃវត្ថុ ដែលអ្នកឱ្យខ្ចី បានប្រគល់ដោយជាក់ស្តែង ចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចី បានប្រគល់ដោយជាក់ស្តែងទៅឱ្យអ្នកខ្ចី ត្រូវចាតទុកថាជាចំនួនប្រាក់ដើម[26]។

**ឧទាហរណ៍៖** លោក **ក** និង លោក **ខ** បានព្រមព្រៀងគ្នាថា លោក **ក** ត្រូវឱ្យលោក **ខ** ខ្ចីប្រាក់ចំនួន ១០០ដុល្លា ក្នុងរយៈពេល ៥ ឆ្នាំ ដោយមានអត្រាការប្រាក់ ២០ភាគរយក្នុង ១ឆ្នាំ។ ប៉ុន្តែលោក **ក** បានប្រគល់ប្រាក់ទៅឱ្យលោក **ខ** ត្រឹមតែ ២០ដុល្លាប៉ុណ្ណោះ ពីព្រោះលោក **ក** ព្យាយាមកាត់ប្រាក់ ៨០ដុល្លា ពីប្រាក់ដើម សម្រាប់ជាការប្រាក់ក្នុងរយៈពេល ៥ឆ្នាំ។ ក្នុងករណីនេះលោក **ខ** មិនអាចប្រើប្រាក់ ១០០ដុល្លានោះទេ ប៉ុន្តែគាត់បែរជាជាប់បំណុល ចំនួន១០០ដុល្លាទៅវិញ ដើម្បីចៀសវាងនូវបញ្ហានេះ មាត្រា ៥៨៥ កថាខណ្ឌទី៥ បានកំណត់ថា ចំនួនទឹកប្រាក់នៃវត្ថុ ដែលត្រូវបានប្រគល់ដោយជាក់ស្តែងត្រូវទុកថាជា ចំនួនប្រាក់ដើម។ បើយកមាត្រានេះមកអនុវត្តនោះ ប្រាក់ដើមគឺ មានចំនួនត្រឹមតែ២០ដុល្លាតែប៉ុណ្ណោះ។

**ខ.ត្រូវចាត់ទុកជាការប្រាក់**

ប្រាក់ និងវត្ថុផ្សេងទៀត ដែលអ្នកឱ្យខ្ចីបានទទួលក្រៅពីប្រាក់ដើម ទាក់ទងទៅនឹងកិច្ចសន្យាខ្ចីបរិភោគត្រូវចាត់ទុកថាជាការប្រាក់ [27] ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តបានឡើយចំពោះសោហ៊ុយនៃការធ្វើកិច្ចសន្យា និងសោហ៊ុយនៃការសង។

បើទោះជាច្បាប់ ដាក់កម្រិតលើអត្រាការប្រាក់ ឬកាត់នូវការប្រាក់ ក៏អ្នកឱ្យខ្ចីដែលមានគោលបំណងអាក្រក់តែងតែព្យាយាមទទួលយកប្រាក់ពីអ្នកខ្ចី ដូចជា ប្រាក់កម្រៃជើងសារ កម្រៃស៊ើប

[26] មាត្រា ៥៨៥ កថាខណ្ឌទី៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[27] មាត្រា ៥៨៦ កថាខណ្ឌទី៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អង្កេត ជាដើម។ ដូច្នេះក្រមរដ្ឋប្បវេណី បានបញ្ញត្តិថា ប្រសិនបើអ្នកឱ្យខ្ចីបានទទួលប្រាក់ ឬវត្ថុផ្សេង ក្រៅពីប្រាក់ដើមនោះ វានឹងត្រូវបានគេចាត់ទុកថាជា ការប្រាក់។

### ២.៤.២.ការប្រាក់សមាស

ការប្រាក់សមាសសំដៅទៅលើការបន្ថែមការប្រាក់លើប្រាក់ដែលបង្កើតរួចហើយ ក្នុងករណីកូនបំណុលមិនព្រមសងការប្រាក់នោះ។ ដោយសារតែការប្រាក់សមាសបានបន្ថែមបន្ទុកដល់អ្នកខ្ចី ការប្រាក់សមាសនេះអាចធ្វើបានលុះត្រាតែ មានការយឺតយ៉ាវ មិនបានបង់ការប្រាក់សម្រាប់រយៈពេលចាប់ពី១ឆ្នាំឡើងទៅ និងករណីដែលអ្នកឱ្យខ្ចីបានដាស់តឿនឱ្យសងតែកូនបំណុលមិនព្រមសង[28]។

### ២.៤.៣.ពេលវេលានៃការបង់ប្រាក់

ការបង់ការប្រាក់ជាកាតព្វកិច្ចរបស់អ្នកខ្ចីក្នុងការបង់ជារៀងរាល់ឆ្នាំម្តង ដែលគិតចាប់ពីថ្ងៃដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ។ ដោយឡែកតាមច្បាប់ អាត្រាការប្រាក់ដែលត្រូវបានកម្រិតសំដៅទៅលើអាត្រាការប្រាក់អតិបរមាដែលអាចកំណត់បានដោយស្របច្បាប់ តាមការព្រមព្រៀងរបស់ភាគី ដែលកំណត់ដោយច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត[29]។

ដូចនេះច្បាប់មិនបានបញ្ញត្តិ ដែលតម្រូវឱ្យបង់ជាកំហិតនោះទេ ភាគីអាចព្រមព្រៀងគ្នាផ្សេងពីលក្ខខណ្ឌនេះបាន ដោយកំណត់នូវការបង់ក្នុងរយៈពេល គិតជាថ្ងៃ ខែ ឬកន្លះឆ្នាំម្តងក៏បាន។

[28] មាត្រា ៥៨៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[29] មាត្រា ៥៨៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី៣៖ អានុភាពនៃកិច្ចសន្យាខ្ចីបរិភោគ

កិច្ចសន្យាខ្ចីបរិភោគ គឺជាកិច្ចសន្យាទ្វេភាគីដែលភាគីត្រូវអនុវត្តឱ្យគ្នាទៅវិញទៅមករវាងគ្នានឹងគ្នា។ ដូចនេះ នៅក្រោយពេលបង្កើតកិច្ចសន្យានោះ នឹងមានអនុភាពចំពោះភាគីនៃកិច្ចសន្យាក្នុងការអនុវត្ត។

## ៣.១.សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី

ដោយសារកិច្ចសន្យាខ្ចីបរិភោគជាកិច្ចសន្យាទ្វេភាគី ហេតុនេះហើយទើបគូភាគីនៃកិច្ចសន្យាខ្ចីបរិភោគត្រូវមានកាតព្វកិច្ចផ្តល់នូវប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។

### ៣.១.១.សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីអ្នកឲ្យខ្ចី

អ្នកឱ្យខ្ចី គឺមានករណីយកិច្ចប្រគល់នូវវត្ថុឱ្យទៅអ្នកខ្ចីស្របតាមកិច្ចសន្យា។ ការខ្ចីបរិភោគគឺអ្នកឱ្យខ្ចីផ្តល់នូវសិទ្ធិ ចាត់ចែង ប្រើបាស់ និងអាស្រ័យផល ចំពោះវត្ថុដែលបានប្រគល់ឱ្យទៅអ្នកខ្ចីនោះ។

#### ៣.១.១.១.ករណីយឱ្យខ្ចីវត្ថុដែលជាកម្មវត្ថុ

អ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់វត្ថុឱ្យអ្នកខ្ចីប្រើប្រាស់ដោយស្របតាមកិច្ចសន្យា រីឯអ្នកខ្ចីអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុ ដោយសេរីបាន(មាត្រា ៥៨៧ នៃក្រមរដ្ឋប្បវេណី) ព្រោះអ្នកខ្ចីបានទទួលកម្មសិទ្ធិលើវត្ថុនោះ[30]។

**ឧទាហរណ៍៖** លោក **ក** បានខ្ចីគ្រាប់សណ្តែកពីលោក **ខ** ចំនួន ៥គីឡូក្រាម។ លោក **ខ** ក៏បានយល់ព្រមក្នុងការឱ្យខ្ចី ដោយឱ្យគ្រាប់សណ្តែកទៅលោក **ក** តាមចំនួនដែលខ្ចីនោះ។ ក្នុងករណីនេះ លោក **ក** មានសិទ្ធិគ្រប់យ៉ាងទៅលើគ្រាប់សណ្តែកនោះ ដោយផ្អែកតាមខ្លឹមសារខាងលើគឺលោក **ក** អាចមានសិទ្ធិក្នុងការប្រើប្រាស់ យកទៅលក់ ឬក៏យកទៅដាំដុះដោយសេរី អាស្រ័យទៅតាមតម្រូវការរបស់លោក **ក** ។ ដូច្នេះលោក **ខ** គ្មានសិទ្ធិក្នុងការហាមឃាត់ ចំពោះការប្រើប្រាស់ អាស្រ័យផល ឬចាត់ចែងរបស់លោក **ក** បាននោះទេ ពីព្រោះក្រមរដ្ឋប្បវេណីបានចែងយ៉ាងច្បាស់ក្នុងចំណុចនេះ។

[30] សៀវភៅពន្យល់ក្រមរដ្ឋប្បវេណី ភាគ៣ ទំព័រទី១០៩

### ៣.១.១.២.ភារៈទទួលខុសត្រូវក្នុងការធានារបស់ភាគីអ្នកឱ្យខ្ចី

កិច្ចសន្យាខ្ចីបរិភោគ ជាកិច្ចសន្យាមួយដែលភាគីនៃកិច្ចសន្យាមានកាតព្វកិច្ចផ្តល់ឱ្យគ្នាទៅវិញទៅមក ហើយចំពោះវត្ថុដែលប្រគល់ឱ្យអ្នកខ្ចីនោះ អ្នកឱ្យខ្ចីត្រូវមានកាតព្វកិច្ចក្នុងការធានាទទួលខុសត្រូវលើវត្ថុនោះ។

### ៣.១.១.៣.ករណីដែលអ្នកខ្ចីបានប្រគល់វត្ថុដែលជារបស់អ្នកដទៃ

ប្រសិនបើភាគីអ្នកឱ្យខ្ចី បានយកវត្ថុរបស់តតិយជនមកដាក់ខ្ចីទៅឱ្យអ្នកខ្ចីនោះ អ្នកឱ្យខ្ចីនោះត្រូវធានានូវលក្ខខណ្ឌមួយចំនួន ដែលបង្ហាញថាអ្នកឱ្យខ្ចីមានកំហុស ឬ គ្មានកំហុសចំពោះករណីដែលយកវត្ថុជាកម្មវត្ថុនៃកិច្ចសន្យាមកឱ្យអ្នកខ្ចី។

- **ករណីខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់**

នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ អ្នកឱ្យខ្ចីដែលបានប្រគល់វត្ថុដែលមិនស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន មានករណីយកិច្ចត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិនៃវត្ថុនោះ ហើយផ្ទេរទៅអ្នកខ្ចី ឬត្រូវប្តូរជាមួយនឹងវត្ថុផ្សេងទៀតដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន។ ប៉ុន្តែ អ្នកខ្ចីមិនអាចធ្វើការទាមទារនូវវត្ថុជំនួសបានទេក្នុងករណីដែលអ្នកខ្ចីបានបរិភោគវត្ថុដែលជាកម្មវត្ថុនៃការខ្ចីរួចនោះ [31]។

បើអ្នកឱ្យខ្ចី មិនអាចប្រគល់វត្ថុនោះបាន ឬមិនអាចរកវត្ថុផ្សេងមកជំនួសបានទេ អ្នកខ្ចីមានសិទ្ធិរំលាយកិច្ចសន្យាខ្ចីបរិភោគនោះបាន ទោះបីជាអ្នកខ្ចីនោះសុចរិត ឬទុច្ចរិតក៏ដោយ[32]។

ទន្ទឹមនឹងនេះផងដែរ ប្រសិនបើអ្នកខ្ចីដែលបានទទួលការប្រគល់វត្ថុខ្ចី ដោយមិនបានដឹងថាអ្នកឱ្យខ្ចី មិនមានកម្មសិទ្ធិទេ អាចទាមទារសំណងនៃការខូចខាតពីអ្នកឱ្យខ្ចីបាន (មាត្រា ៥៨៨ កថាខណ្ឌទី ៣)។

ក្នុងករណីនេះ បើអ្នកខ្ចីបានសងវត្ថុដែលត្រូវបានប្រគល់ឱ្យ ឬសងតម្លៃនៃវត្ថុនោះ ឱ្យទៅម្ចាស់កម្មសិទ្ធិនោះ អ្នកខ្ចីត្រូវបានរួចផុតពីករណីយកិច្ច សងចំពោះអ្នកឱ្យខ្ចី[33]។

---

[31] មាត្រា ៥៨៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[32] មាត្រា ៥៨៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[33] មាត្រា ៥៨៨ កថាខណ្ឌទី៥ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**• ករណីខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់**

ចំណែកឯកិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់ បានន័យថាការខ្ចីបរិភោគនោះមិនគិតតម្លៃថ្នូរ ដូចនេះអ្នកឱ្យខ្ចីមិនទាមទារ ឬតម្រូវឱ្យអ្នកខ្ចីបង់ការប្រាក់ទេ។ ក្នុងករណីនេះ ប្រសិនបើអ្នកឱ្យខ្ចីដឹងថាវត្ថុដែលប្រគល់នោះជារបស់តតិយជនណាមួយ ហើយអ្នកឱ្យខ្ចីនៅតែមិនប្រាប់អំពីដំណឹងនោះទៅកាន់អ្នកខ្ចីនោះទេ អ្នកឱ្យខ្ចីនឹងត្រូវទទួលខុសត្រូវចំពោះអ្នកខ្ចីដូចក្នុងករណីខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ដែរ[34]។

បើអ្នកខ្ចីបានសងវត្ថុដែលត្រូវបានប្រគល់ឱ្យ ឬសងតម្លៃនៃវត្ថុនោះ ឱ្យទៅម្ចាស់កម្មសិទ្ធិនោះ អ្នកខ្ចីត្រូវបានរួចផុតពីករណីយកិច្ច សងចំពោះអ្នកឱ្យខ្ចី។

**• សិទ្ធិក្នុងការរំលាយរបស់អ្នកខ្ចីចំពោះវត្ថុអ្នកដទៃ**

នៅក្នុងកិច្ចសន្យាខ្ចីបរិភោគ អ្នកឱ្យខ្ចីមានសិទ្ធិរំលាយកិច្ចសន្យាបានចំពោះករណីដែលមិនបានដឹងពីកម្មវត្ថុរបស់ខ្លួនដែលបានផ្ទេរនោះថា ជាកម្មសិទ្ធិតតិយជន ឬជនណាមួយ។ បន្ថែមពីលើនេះផងដែរ អ្នកខ្ចីមិនអាចផ្ទេរកម្មសិទ្ធិទៅលើវត្ថុ ឬវត្ថុជំនួសទៅឱ្យអ្នកខ្ចីដូចបានចែងក្នុងកិច្ចសន្យាបាននោះឡើយ[35]។

យ៉ាងណាមិញប្រសិនបើអ្នកខ្ចីបានធ្វើសកម្មភាពដែលសុចរិតនោះ គឺអ្នកខ្ចីមានសិទ្ធិក្នុងការទាមទារសំណងនៃការខូចខាតដែលបានកើតឡើងចេញពីសកម្មភាពនោះបាន។

**ឧទាហរណ៍៖** លោក **ក** បានប្រគល់សាច់គោឱ្យលោក **ខ** ដោយបានដឹងថា សាច់គោនោះគឺជាកម្មសិទ្ធិរបស់ លោក **គ**។ លោក **ខ** គឺជាអ្នកគ្រប់គ្រងនៅហាងអាហារមួយ ប៉ុន្តែគាត់មិនអាចបើកហាងបានក្នុងរយៈពេល ៤ ថ្ងៃ ព្រោះគាត់ត្រូវសងសាច់គោនោះទៅឱ្យលោក **គ** វិញដោយផ្អែកលើមាត្រា ៥៨៨ កថាខណ្ឌទី៣។ នៅក្នុងករណីនេះ លោក **ក** អាចរំលាយកិច្ចសន្យាបាន ប៉ុន្តែគាត់ត្រូវសងប្រាក់ចំណូលនៅក្នុងរយៈពេល ៣ថ្ងៃ ទៅឱ្យលោក **ខ** នៅមុនពេលរំលាយ។

[34] មាត្រា ៥៨៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[35] មាត្រា ៥៨៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**៣.១.១.៤.ករណីវត្ថុមានវិការៈ**

ក្នុងន័យនេះវិការៈសំដៅទៅលើវិការៈនៅក្នុងកិច្ចសន្យា ដែលវិការៈនេះគូភាគីនៃកិច្ចសន្យាអាចមើលឃើញ ហើយពេលខ្លះវាមិនអាចមើលឃើញដោយភ្នែកជាក់ស្តែងបាននោះទេ។ សម្រាប់កិច្ចសន្យាខ្ចីបរិភោគនេះច្រើនកើតមានឡើងនូវវិការៈកំបាំង ដែលជាហេតុនាំឱ្យកើតមាននូវវិវាទឈ្លោះប្រកែកគ្នារវាងភាគីអ្នកឱ្យខ្ចី និងភាគីអ្នកខ្ចី។ វិការៈកំបាំងនេះគឺទាមទារឱ្យមានអ្នកបច្ចេកទេស និងជំនាញ ក្នុងការពិនិត្យមើល វិភាគ ឬវិនិច្ឆ័យ ទើបដឹងថាវត្ថុនោះមានវិការៈកំបាំង ឬមួយក៏អត់។

- **ករណីខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់**

នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ប្រសិនបើមានវិការៈកំបាំងនៅក្នុងវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ អ្នកខ្ចីដែលបានទទួលការប្រគល់នោះដោយមិនដឹងអំពីវិការៈនោះ អាចទាមទារឱ្យប្តូរជាមួយនឹងវត្ថុដែលគ្មានវិការៈ និង អាចទាមទារសំណងនៃការខូចខាតបាន[36]។ បានសេចក្តីថាការប្រគល់នូវវត្ថុដែលមានវិការៈទៅឱ្យអ្នកខ្ចី ហើយអ្នកខ្ចីបានទទួលយកនូវវត្ថុនោះដោយមិនដឹងអំពីវិការដែលមានលើវត្ថុនោះ ដូច្នេះអ្នកខ្ចីមានសិទ្ធិក្នុងការទាមទារឱ្យភាគីអ្នកឱ្យខ្ចី ធ្វើការផ្លាស់ប្តូរវត្ថុដែលមានវិការៈនោះបាន។ មិនត្រឹមតែប៉ុណ្ណោះភាគីអ្នកឱ្យខ្ចីអាចទាមទារចំពោះសំណងការខូចខាតពីលើបានទៀត ក្នុងករណីដែលអ្នកខ្ចីដឹងថាវត្ថុដែលភាគីអ្នកឱ្យខ្ចីប្រគល់មកនោះមានវិការៈស្រាប់។

- **ករណីខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់**

កិច្ចសន្យាខ្ចីបរិភោគដែលគ្មានភ្ជាប់ការប្រាក់ អ្នកខ្ចីដែលបានទទួលការប្រគល់វត្ថុដែលមានវិការៈ អាចសងតម្លៃនៃវត្ថុដែលមានវិការៈបាន [37]។ ការខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់នេះ នៅពេលដែលវត្ថុក្នុងកិច្ចសន្យាមានវិការៈនោះអ្នកឱ្យខ្ចីត្រូវធ្វើការទទួលខុសត្រូវចំពោះការខូចខាត ប៉ុន្តែការទទួលខុសត្រូវនោះមានលក្ខណៈតិចតួចប៉ុណ្ណោះ។ ករណីដែលវត្ថុនោះមានវិការៈដោយសារអ្នកខ្ចី អ្នកខ្ចីអាចសងជាប្រាក់ក៏បានតែត្រូវឱ្យមានតម្លៃស្មើនឹងវត្ថុនោះ។ ចំណែកឯអ្នកឱ្យខ្ចីវិញ

[36] មាត្រា ៥៩០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[37] មាត្រា ៥៩០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ប្រសិនបើដឹងអំពីវិការៈនៃវត្ថុនោះមុនពេលដែលប្រគល់ឱ្យអ្នកខ្ចី នោះអ្នកឱ្យខ្ចីធ្វើការប្តូរនូវវត្ថុថ្មីដែលគ្មានវិការៈជំនួស និងត្រូវសងចំពោះការខូចខាតដែលបណ្តាលមកពីកំហុសរបស់ខ្លួន។

**ឧទាហរណ៍៖** លោក **ក** បានប្រគល់ត្រីចំនួន ៥គីឡូក្រាម ទៅឱ្យលោក **ខ** ដោយការបរិភោគមិនភ្ជាប់ការប្រាក់ ប៉ុន្តែនៅក្នុងនោះមានត្រីចំនួន ២គីឡូក្រាមដែលមានគុណភាពអន់ ហើយតម្លៃរបស់វាមានត្រឹមតែ ១ ភាគ ១០ នៃតម្លៃទីផ្សារតែប៉ុណ្ណោះ។ នៅក្នុងករណីនេះ លោក **ខ** អាចសងត្រីចំនួន ៨គីឡូក្រាម ដែលមានគុណភាពដូចត្រីដើមដែលគាត់បានទទួល និងតម្លៃ ១ ភាគី ១០ នៃតម្លៃទីផ្សារ។

#### ៣.១.១.៥.ការទាមទារឱ្យសងមកវិញក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីបានធ្លាក់ចុះ

នៅចន្លោះពេលដែលកិច្ចសន្យាបានបង្កើតឡើង រហូតដល់ពេលដែលប្រគល់វត្ថុដែលជាកម្មវត្ថុ ប្រសិនបើស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីធ្លាក់ចុះយ៉ាងខ្លាំង ដែលនឹងអាចឱ្យមានឧបសគ្គដល់ការអនុវត្តកាតព្វកិច្ចសង អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាខ្ចីបរិភោគបាន[38]។

ដោយឡែក អ្នកខ្ចីមានសិទ្ធិប្រើប្រាស់វត្ថុដែលបានផ្តល់ឱ្យរហូតដល់ពេលប្រគល់ ឬអាចនិយាយបានថា អ្នកខ្ចីមិនចាំបាច់ប្រគល់វត្ថុ នៅមុនកាលបរិច្ឆេទសងនោះទេ។ ដោយយោងតាមមាត្រា ៥៩៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ អ្នកឱ្យខ្ចី មិនត្រូវអនុញ្ញាតឱ្យធ្វើការទាមទារសងវត្ថុ នៅមុនកាលបរិច្ឆេទសងឡើយ ( ដែលចំណុចនេះគេហៅថា ផលប្រយោជន៍នៃការកំណត់ពេលវេលា )។ ប៉ុន្តែចំណុចនេះមិនត្រូវយកមកអនុវត្តបានទេ ក្នុងករណីដែលអ្នកខ្ចីត្រូវបានប្រកាសក្ស័យធន ,ធ្វើឱ្យខូចខាតប្រតិភោគ ,មិនបំពេញករណីយកិច្ចក្នុងការដាក់ប្រតិភោគ និងគូភាគីបានព្រមព្រៀងគ្នា[39]។

ប៉ុន្តែក្នុងករណីដែលចំណុចមិនអនុវត្តនោះកើតមានឡើង កូនបំណុលត្រូវបាត់បង់ផលប្រយោជន៍នៃការកំណត់អំឡុងពេល ហើយជាលទ្ធផលគាត់ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនជាបន្ទាន់។ **ឧទាហរណ៍៖** ប្រសិនបើអ្នកខ្ចី ត្រូវបានប្រកាសក្ស័យធននោះ គាត់ត្រូវសងវត្ថុខ្ចីមកវិញភ្លាម។

[38] មាត្រា ៥៨១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[39] មាត្រា ៣៣១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ទន្ទឹមនឹងនេះផងដែរ "ចំពោះករណីដែល ហេតុភាគីមានការព្រមព្រៀងគ្នា បានកើតឡើង" នោះកូនកំណុលក៏ត្រូវបានបាត់បង់ផលប្រយោជន៍នៃពេលដែរ។

**ឧទាហរណ៍៖** "ចំពោះករណីដែល ហេតុភាគីមានការព្រមព្រៀងគ្នា បានកើតឡើង" ចំណុចនេះគេបានរាប់បញ្ចូល ដូចជា ការព្រមព្រៀងពិសេសដែលចែងថា" ប្រសិនបើមានមូលហេតុដែលអ្នកខ្ចី មិនបង់ប្រាក់ចំនួន ៥ខែនោះ អ្នកឱ្យខ្ចីមិនអាចទាមទារឱ្យបង់ភ្លាមៗ នូវប្រាក់បំណុលដែលនៅសល់ទាំងអស់ ដោយមិនចាំបាច់ធ្វើការជូនដំណឹងជាមុននោះទេ " ឬ " នៅក្នុងករណីដែលទ្រព្យសម្បត្តិរបស់អ្នកខ្ចី ត្រូវបានរឹបអូសដោយម្ចាស់បំណុលផ្សេងទៀត នោះអ្នកខ្ចីត្រូវបាត់បង់ផលប្រយោជន៍នៃការកំណត់អំឡុងពេល និងត្រូវសងបំណុលភ្លាម "។

### ៣.១.២. សិទ្ធ និងភាតព្វកិច្ចរបស់អ្នកខ្ចី

ការខ្ចីបរិភោគ គឺភាគីនៃកិច្ចសន្យាមានសិទ្ធិ និងករណីកាតព្វកិច្ចដែលត្រូវអនុវត្តចំពោះគ្នាទៅវិញទៅមក។ ក្នុងចំណុចនេះគេសង្កត់ធ្ងន់ទៅលើសិទ្ធិរបស់អ្នកខ្ចីដែលមាននៅក្នុងកិច្ចសន្យាខ្ចីបរិភោគ ហើយអ្នកខ្ចីត្រូវមានធ្វើការអនុវត្តកាតព្វកិច្ចដែលខ្លួនមានចំពោះការព្រមព្រៀងជាមួយអ្នកខ្ចី។

#### ៣.១.២.១.ករណីកិច្ចសងនូវវត្ថុ

អ្នកខ្ចីមានករណីត្រូវសងទៅអ្នកឱ្យខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួនស្មើគ្នានឹងវត្ថុដែលទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង [40] ។ បានន័យថានៅពេលដែលដល់ពេលវេលាកំណត់នៃការព្រមព្រៀងក្នុងកិច្ចសន្យា ភាគីអ្នកខ្ចីត្រូវសងវត្ថុដែលមានចំនួន បរិមាណ ប្រភេទ និងគុណភាពដែលដូចទៅនឹងវត្ថុដើមដែលអ្នកឱ្យខ្ចីប្រគល់ឱ្យនោះ។

**ឧទាហរណ៍៖** ប្រសិនបើអ្នកខ្ចី បានខ្ចីអង្ករប្រភេទ អង្ករផ្ការំដួលចំនួន ១០០គីឡូក្រាម ពីអ្នកឱ្យខ្ចី សម្រាប់រយៈពេល ១ឆ្នាំ និងបានសន្យាថានឹងឱ្យការប្រាក់ ១០ភាគរយក្នុងមួយឆ្នាំ។ នៅពេលដែលដល់ពេលវេលានៃការសង អ្នកខ្ចី ត្រូវតែសងអង្ករប្រភេទផ្ការំដួល ដែលមានគុណភាព ដូចអង្ករ

[40] មាត្រា ៥៩១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដែលបានខ្ចីពីអ្នកឱ្យខ្ចី ក្នុងបរិមាណ ១០០គីឡូក្រាម និងការប្រាក់ ១០គីឡូជាកថ្ងៃនៃការខ្ចីនោះ សរុបទាំងអស់ គឺ ១១០គីឡូក្រាម នៅថ្ងៃកំណត់សង។

អ្នកខ្ចីមិនអាចសងនូវវត្ថុ ដែលមានបរិមាណតិចជាង ហើយអ្នកឱ្យខ្ចីផ្តល់នូវការសងវត្ថុ ដែលមានបរិមាណច្រើនជាងបរិមានដែលបានកំណត់នៅក្នុងកិច្ចសន្យានោះទេ លើកលែងតែភាគីទាំងពីរបានព្រមព្រៀងគ្នា។ ប្រសិនបើ ការសងមិនបានបំពេញគ្រប់នូវលក្ខខណ្ឌដែលបានកំណត់ខាងលើនេះទេ អ្នកឱ្យខ្ចី អាចបដិសេធមិនទទួលយកនូវការសង ដោយមូលហេតុណាមួយ ដូចជា ភាពខុសគ្នានៃប្រភេទ បរិមាណ ឬគុណភាព ហើយអ្នកឱ្យខ្ចីអាចទាមទារឱ្យអ្នកខ្ចីទទួលខុសត្រូវ ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះបាន។

ករណីយកិច្ចដែលត្រូវសង គឺជាករណីយកិច្ចចម្បង និងទូទៅបំផុតរបស់អ្នកខ្ចី ហើយករណីយកិច្ចនេះ គឺត្រូវតែបំពេញឱ្យបាន នៅពេលដែលពេលវេលាកំណត់នៃការសងបានមកដល់ មិនតែប៉ុណ្ណោះ ការសងត្រូវធ្វើឡើងដោយគោរពតាមគោលការណ៍មួយចំនួន ដូចដែលបានកំណត់នៅក្នុងមាត្រា ៥៩១ ដល់ មាត្រា ៥៩៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

**៣.១.២.២.ពេលវេលានៃការសង**

យោងតាមក្រមរដ្ឋប្បវេណីមាត្រា ៥៩៤ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ថាពេលវេលានៃការសងក្នុងកិច្ចសន្យាខ្ចីបរិភោគ ត្រូវបានបែកចែកជា ពីរប្រភេទគឺ ការខ្ចីបរិភោគដោយមានកំណត់អំឡុងពេល និងគ្មានកំណត់អំឡុងពេល។

**ក.កិច្ចសន្យាខ្ចីបរិភោគដែលមានកំណត់អំឡុងពេល**

ចំពោះករណីកិច្ចសន្យាខ្ចីបរិភោគដែលមានកំណត់អំឡុងពេល គឺអ្នកឱ្យខ្ចីគ្មានសិទ្ធិក្នុងការទាមទារឱ្យអ្នកខ្ចីធ្វើការសងវត្ថុដែលបានខ្ចីនោះ មុនពេលដែលបានកំណត់នៃការសងនៅក្នុងកិច្ចសន្យានោះបានឡើយ[41]។ ដោយឡែកការទាមទារឱ្យសងមុនកាលបរិច្ឆេទបាននោះ លុះត្រាតែអ្នកខ្ចីត្រូវបានក្ស័យធន ,បានធ្វើឱ្យខូចខាតប្រាតិភោគ និងមានការព្រមព្រៀងរវាងគូភាគី[42]។

[41] មាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[42] មាត្រា ៣៣១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ខ.កិច្ចសន្យាខ្ចីបរិភោគដែលគ្មានកំណត់អំឡុងពេល

កិច្ចសន្យាខ្ចីបរិភោគដែលមិនមានកំណត់អំឡុងពេល គឺមានវាមានសេរីភាពទូលំទូលាយសម្រាប់ ភាគីនៃកិច្ចសន្យាក្នុងការព្រមព្រៀងគ្នានូវរយៈពេលកំណត់ចំពោះការសងនូវអំឡុងពេលណាមួយសមរម្យដែលអាចសងទៅឱ្យអ្នកឱ្យខ្ចី។ តែប្រសិនបើភាគីនៃកិច្ចសន្យាមិនបានកំណត់កាលបរិច្ឆេទនៃការសងទេ អ្នកឱ្យខ្ចីអាចដាស់តឿនឱ្យសង ដោយកំណត់អំឡុងពេលសមរម្យបាន[43] ។ នៅក្នុងក្រមរដ្ឋប្បវេណី ពុំមានមាត្រាណាមួយដែលចែងអំពីការកំណត់អំឡុងពេលសមរម្យក្នុងការដាស់តឿននេះទេ ហេតុនេះការកំណត់អំឡុងពេលសមរម្យនេះ គឺជាអំឡុងពេលដែលត្រូវការចាំបាច់សម្រាប់អ្នកខ្ចី ក្នុងការរៀបចំ និងសងនូវវត្ថុក្រោយពីបានទទួលនូវការដាស់តឿនពីអ្នកខ្ចី។ ដូច្នេះពេលវេលាអាចធ្វើការសម្រេចបានដោយធ្វើការពិចារណា ទៅលើខ្លឹមសារនៃកិច្ចសន្យាឬចំនួន និងប្រភេទនៃវត្ថុដែលបានខ្ចី។

### គ.ក្នុងករណីខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់

ក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ អ្នកខ្ចីអាចធ្វើការសងនៅមុនកាលបរិច្ឆេទនៃការសងដែលបានកំណត់នៅក្នុងកិច្ចសន្យាបាន។ ប៉ុន្តែនៅក្នុងករណីដែលការសងរបស់អ្នកខ្ចីអាចបណ្តាលឱ្យមានការខូចខាតដល់ផលប្រយោជន៍របស់ភាគីអ្នកឱ្យខ្ចីនោះ ភាគីអ្នកខ្ចីត្រូវផ្តល់សំណងនៃការខូចខាតដល់ភាគីអ្នកឱ្យខ្ចី[44]។

### ឃ.ក្នុងករណីខ្ចីបរិភោគដែលគ្មានភ្ជាប់ការប្រាក់

ក្នុងករណីខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់ អ្នកខ្ចីអាចសងនៅពេលណាក៏បាន ប៉ុន្តែមិនត្រូវឱ្យផុតនូវពេលវេលានៃការសងនោះទេ [45] ។ ប៉ុន្តែនៅក្នុងករណីដែលធ្វើឱ្យមានការខូចខាតដល់អ្នកឱ្យខ្ចី ដោយសារការសងនោះ អ្នកខ្ចីត្រូវសងសំណងនៃការខូចខាតដូចមានចែងនៅក្នុងមាត្រា ៥៩៤ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

---

[43] មាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[44] មាត្រា ៥៩៤ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[45] មាត្រា ៥៩៤ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣.១.២.៣.ទីកន្លែងនៃការសង

ចំពោះការសងនូវវត្ថុ ឬប្រាក់ គូភាគីអាចកំណត់ដោយធ្វើការជ្រើសរើសយកទីកន្លែងណាក៏បាន។ ក្នុងករណីដែលភាគីមិនបានធ្វើការព្រមព្រៀងកំណត់អំពីទីកន្លែងនៃការសងវត្ថុនោះទេ អ្នកខ្ចីអាចយកវត្ថុដែលសងនោះ ទៅសងនៅទីលំនៅឋាន ឬកន្លែងស្នាក់នៅរបស់អ្នកឱ្យខ្ចីបាន។[46]

**ឧទាហរណ៍៖** លោក **ក** បានធ្វើការព្រមព្រៀងគ្នាជាមួយលោក **ខ** នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកំណត់នូវទីតាំងដែលលោក **ក** ត្រូវយកវត្ថុទៅសង ហើយកន្លែងដែលត្រូវសងនោះ គឺនៅក្នុងក្រុមហ៊ុនរបស់លោក **ខ**។ ដូចនេះ នៅពេលដែលដល់កាលកំណត់ដែលត្រូវសងវត្ថុនោះ លោក **ក** ត្រូវតែយកវត្ថុដែលខ្លួនសងនោះ ទៅសងនៅក្រុមហ៊ុនរបស់លោក ខ ។

ផ្ទុយទៅវិញចំពោះឧទាហរណ៍ខាងលើ បើសិនជាលោក **ក** និងលោក **ខ** មិនបានកំណត់នូវតាំងនោះ នៅពេលដែលដល់នូវពេលវេលានៃការសងលោក **ក** អាចយកវត្ថុទៅសង នៅក្រុមហ៊ុននៅកន្លែណាមួយដែលបានណាត់ជួប ឬសងនៅផ្ទះរបស់លោក **ខ** ក៏បានដែរ គឺអាស្រ័យទៅលើភាគីទាំងសងខាង។

### ៣.១.២.៤.ករណីដែលអ្នកខ្ចីមិនអាចសងនូវវត្ថុបាន

ក្នុងករណីអ្នកខ្ចីមិនអាចសងនូវវត្ថុដែលមានប្រភេទ បរិមាណ និងគុណភាពដូចនឹងវត្ថុចាស់ដែលបានខ្ចីនោះទេ អ្នកខ្ចីត្រូវតែធ្វើការសងជាប្រាក់ដែលសមស្របទៅនឹងតម្លៃនៃវត្ថុដើមនោះទៅឱ្យអ្នកខ្ចី[47]។ ពីព្រោះអ្នកខ្ចីមានករណីយកិច្ចត្រូវសងនូវវត្ថុដែលមាន ប្រភេទ គុណភាព និងចំនួន ស្មើគ្នាទៅនឹងវត្ថុដែលបានទទួលការប្រគល់ ឱ្យស្របតាមកាលបរិច្ឆេទដែលត្រូវសង។

**ឧទាហរណ៍៖** លោក **ក** បានខ្ចីស្រូវចំនួន ២០គីឡូពីលោក **ខ** ដោយបានកំណត់អំឡុងពេលនៃការសង។ ស្រាប់តែដល់កាលបរិច្ឆេទនៃការសងលោក **ក** គ្មានស្រូវសម្រាប់សងនោះទេ ប៉ុន្តែលោក **ក** បានសងជាប្រាក់វិញចំនួន ៥ម៉ឺនរៀលជំនួសវិញ។ លោក **ខ** ក៏បានទទួលយកការសងនោះ។

[46] មាត្រា ៥៩៦ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[47] មាត្រា ៥៩២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**៣.១.២.៥.ភាតព្វកិច្ចនៃការបង់ការប្រាក់**

កិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ គឺភាគីអ្នកខ្ចីមានកាតព្វកិច្ចត្រូវតែបង់នូវ ប្រាក់ដែលបានកំណត់នៅក្នុងកិច្ចសន្យា និងព្រមព្រៀងគ្នារួចមកហើយនោះទៅឱ្យអ្នកខ្ចី។ ចំពោះការប្រាក់ដែលតម្រូវឱ្យបង់នោះ ត្រូវអនុលោមទៅតាមច្បាប់ដែលបានកំណត់ ឬតាមការព្រៀមព្រៀងនៅក្នុងកិច្ចសន្យា (ការប្រាក់ត្រង់ចំណុចនេះ មិនត្រូវឱ្យលើសពីការណត់របស់ច្បាប់ដែលបានចែងបានទេ)។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទ "កិច្ចសន្យាខ្ចីបរិភោគ" រួចមកហើយនោះ ហើយសង្កេតឃើញថាកិច្ចសន្យាខ្ចីបរិភោគនេះ គឺពិតជាមានលក្ខណៈពិសេស និងសារសំខាន់ខ្លាំងណាស់ចំពោះជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប។ យ៉ាងណាមិញមនុស្សភាគច្រើនតែងតែធ្វើសកម្មភាពខ្ចីបរិភោគជាញឹកញាប់ ប៉ុន្តែគាត់មិនបានដឹងថាការខ្ចីបែបនេះវាជាកិច្ចសន្យាខ្ចីបរិភោគនោះឡើយ ដោយគាត់គ្រាន់តែគិតថាជាការខ្ចីគ្នាទៅវិញទៅមកក្នុងការជួយគ្នានៅពេលដែលមានជួបការលំបាកខ្វះខាតម្តងម្កាលតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះផងដែរ បើយើងក្រឡេកមើលទៅលើក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជាយើងវិញ គឺកិច្ចសន្យាខ្ចីបរិភោគមួយនេះជាកិច្ចសន្យាមួយដែលមានចំណងគតិយុត្តរវាងអ្នកឱ្យខ្ចី និងអ្នកឱ្យខ្ចី។ ថ្វីត្បិតតែកិច្ចសន្យានេះមានលក្ខខណ្ឌសុពលភាពដូចជាកិច្ចសន្យាទូទៅក៏ពិតមែន ប៉ុន្តែកិច្ចសន្យាមួយនេះមានលក្ខខណ្ឌពិសេសមួយចំនួនដែលតម្រូវឱ្យគូភាគីត្រូវគោរពតាមផងដែរ។ ក្នុងការកិច្ចសន្យាខ្ចីបរិភោគនេះ គឺមានការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ និងដោយគ្មានភ្ជាប់ការប្រាក់។ កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ គឺអ្នកខ្ចីដែលអ្នកខ្ចីមានករណីយកិច្ចក្នុងការបង់ការប្រាក់ដែលជាតម្លៃថ្នូរនៃការខ្ចីបរិភោគនោះទៅតាមពេលវេលាដែលបានកំណត់នៅក្នុងកិច្ចសន្យា។ ចំណែកឯកិច្ចសន្យាសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់វិញ គឺការខ្ចីបរិភោគដោយមិនគិតពីតម្លៃថ្នូរនៃការខ្ចីនោះឡើយ ក្នុងករណីនេះអ្នកឱ្យខ្ចីមិនអាចទាមទារ ឬក៏តម្រូវឱ្យភាគីបង់នូវការប្រាក់នោះឡើយ។

កិច្ចសន្យាខ្ចីបរិភោគត្រូវបានបង្កើតឡើងនៅពេលដែលបុគ្គលពីរបានព្រៀមគ្នាក្នុងការបង្កើតកិច្ចសន្យា ដែលប្រកបដោយឆន្ទៈពិតរវាងគ្នានឹងគ្នាក្នុងគោលបំណងខ្ចីបរិភោគវត្ថុ ឬប្រាក់។ ហើយនៅក្នុងការខ្ចីបរិភោគនេះភាគីអាចកំណត់ថា ត្រូវខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ ឬខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់ក៏បាន គឺអាស្រ័យទៅលើការព្រមព្រៀងរបស់គូភាគីនៃកិច្ចសន្យាជាអ្នកកំណត់ប៉ុណ្ណោះ។ បន្ទាប់ពីគោរពតាមលក្ខខណ្ឌនៃសុពលភាព និងធ្វើការកំណត់យកនូវប្រភេទនៃការខ្ចីបរិភោគរួចហើយនោះ កិច្ចសន្យានោះនឹងមានអានុភាពនៅពេលដែលអ្នកឱ្យខ្ចីបានប្រគល់ វត្ថុ ឬប្រាក់ដែលជាកម្មវត្ថុនោះឱ្យទៅអ្នកខ្ចី។

សរុបសេចក្តីមក កិច្ចសន្យាខ្ចីបរិភោគ ជាកិច្ចសន្យាមួយដែលអ្នកឱ្យខ្ចីមានឆន្ទៈក្នុងការប្រគល់នូវ វត្ថុ ឬប្រាក់ឱ្យទៅអ្នកខ្ចី ហើយការប្រគល់នោះគឺអ្នកឱ្យខ្ចីប្រគល់ទាំងសិទ្ធិក្នុង ប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទៅឱ្យអ្នកខ្ចីផងដែរ។ យ៉ាងណាមិញ ភាគីទាំងសងខាងនៃកិច្ចសន្យាត្រូវតែបំពេញនូវសិទ្ធិ និងករណីយកិច្ចចំពោះគ្នាទៅវិញទៅមក។ ក្នុងករណីដែលភាគីណាមួយមិនធ្វើការអនុវត្ត ឬធ្វើឱ្យមានកំហុសខុសឆ្គងពីអ្វីដែលមានចែងនៅក្នុងកិច្ចសន្យានោះ ភាគីដែលបំពាន ឬក៏សាងនូវកំហុសនោះនឹងត្រូវទទួលខុសត្រូវចំពោះភាគីម្ខាងទៀតទៅច្បាប់ដែលមានចែង មិនថានៅក្នុងការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ និងការខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់នោះទេ។

# អនុសាសន៍

# អនុសាសន៍

ដោយផ្អែករយៈការស្រាវជ្រាវទៅលើប្រធានបទ កិច្ចសន្យាខ្ចីបរិភោគរួចមក យើងខ្ញុំសូមផ្តល់នូវអនុសាសន៍ក្នុងន័យកែលំអរ ដើម្បីជាប្រយោជន៍ចំពោះការអនុវត្តកិច្ចសន្យាខ្ចីបរិភោគ និងការពារកុំមានវិវាទកើតមានឡើង។

ចំពោះកិច្ចសន្យាខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់ គឺគួរតែតម្រូវឱ្យមានការធ្វើជាលាយលក្ខណ៍ជាអក្សរដូចទៅនឹងកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ដែរ ព្រោះគោលបំណងរបស់អ្នកខ្ចី គឺខ្ចីវត្ថុ ឬទ្រព្យដើម្បីយកទៅប្រើប្រាស់ អាស្រ័យផល និងចាត់ចែងតាមទៅតាមតម្រូវការរបស់ខ្លួនក្នុងប្រកបរបរអ្វីមួយ ឬក៏ធ្វើអ្វីមួយដែលជាប្រយោជន៍របស់ខ្លួន។ ដោយឡែកប្រសិនបើការខ្ចីនោះធ្វើឡើងដោយគ្មានភ្ជាប់ការប្រាក់ ដែលមិនមានការធ្វើជាលិខិតខ្ចីបរិភោគនោះគឺ អ្នកឱ្យខ្ចីមានសិទ្ធិក្នុងការដកហូតនូវវត្ថុដែលជាកម្មវត្ថុនោះពេលណាក៏បាន ដូច្នេះការដកហូតបែបនេះអាចធ្វើឱ្យមានផលប៉ះពាល់ដល់ដំណើរការ ឬសកម្មភាពណាមួយដែលចាំបាច់ត្រូវមានវត្ថុដែលជាកម្មវត្ថុនោះដើម្បីដំណើរការក្នុងការទាញយកប្រយោជន៍របស់អ្នកខ្ចី។

ចំណែកឯ ក្នុងករណីការកំណត់អំពីអំឡុងពេលសមរម្យក្នុងការសងវត្ថុដែលភាគីអ្នកឱ្យខ្ចីបានធ្វើការដាស់តឿន ដែលស្ថិតនៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលគ្មានកំណត់អំឡុងពេល។ ត្រង់ចំណុចនេះច្បាប់គួរតែធ្វើការកំណត់ឱ្យបានច្បាស់លាស់ចំពោះអំឡុងពេលសមរម្យ ពីព្រោះអំឡុងពេលសមរម្យនេះ វាមានសារៈប្រយោជន៍ចំពោះអ្នកខ្ចីក្នុងរៀបចំ និងសងនូវវត្ថុ ក្រោយពីទទួលបានពីការដាស់តឿនពីអ្នកឱ្យខ្ចី។

ដូច្នេះយើងខ្ញុំសង្ឃឹមថាក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជានឹងធ្វើការបញ្ញត្តិឱ្យបានច្បាស់លាស់ ចំពោះការធ្វើលិខិតជាលាយលក្ខណ៍អក្សក្នុងករណីខ្ចីបរិភោគដោយគ្មានភ្ជាប់ការប្រាក់ និងការកំណត់អំពីអំឡុងពេលសមរម្យក្នុងការសង ក្រោយពីអ្នកខ្ចីបានទទួលបានការដាស់តឿនពីអ្នកឱ្យខ្ចី។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។
- ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី។
- ក្រឹត្យ-ច្បាប់លេខ៣៨ ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា
- ប្រកាសស្ដីពីអាត្រាការប្រាក់ដែលត្រូវបានកម្រិត

## សៀវភៅ

- សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី
- សៀវភៅពន្យល់ក្រមរដ្ឋប្បវេណី ភាគ៣
- ញឹក វុទ្ធី នីតិកាតព្វកិច្ច ភាគ១ និង ២

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# ក្រមរដ្ឋប្បវេណី

# ឆ្នាំ២០០៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមរដ្ឋប្បវេណី

ឆ្នាំ ២០០៧

# ព្រះរាជក្រម

នស/រកម/១២០៧/០៣៧

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ក្រមរដ្ឋប្បវេណី

មានភ្ជាប់បន្ទុក បុគ្គលនោះអាចទាមទារ ចំពោះភាគីម្ខាងទៀតឱ្យផ្តល់តាវកាលិកបាន ។

៤-នៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក បើគ្មានកិច្ចសន្យាពិសេសទេ លុះត្រាតែភាគីម្ខាងមិនបានធ្វើការផ្តល់តាវកាលិកទេ ទើបភាគីម្ខាងទៀតនៃកិច្ចសន្យា អាចមិនផ្តល់តាវកាលិករបស់ខ្លួនបាន ។

៥-ទាយកនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក អាចរំលាយកិច្ចសន្យាប្រទានកម្មដែលមានភ្ជាប់បន្ទុកនោះ តាមបញ្ញត្តិនៃការរំលាយកិច្ចសន្យាបាន នៅក្នុងករណីដែលភាគីម្ខាងទៀតមិនបានអនុវត្តបន្ទុក ។

**មាត្រា ៥៧៧.–** ប្រទានកម្មដោយមូលហេតុមរណភាព

១-ប្រទានកម្មដែលបង្កើតអានុភាពដោយមរណភាពរបស់ទាយក ត្រូវហៅថាប្រទានកម្មដោយមូលហេតុមរណភាព ។

២-បញ្ញត្តិនៃអច្ច័យទាន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃប្រទានកម្មដោយមូលហេតុមរណភាព ។

## ជំពូកទី ៤
## ការខ្ចីបរិភោគ

### ផ្នែកទី ១
### និយមន័យ និង ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

**មាត្រា ៥៧៨.–** និយមន័យនៃការខ្ចីបរិភោគ

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ឬ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពី

អ្នកឱ្យខ្ចីនោះ ។

**មាត្រា ៥៧៩.–** ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

កិច្ចសន្យាខ្ចីបរិភោគត្រូវបង្កើតឡើង ដោយការព្រមព្រៀងរវាងអ្នកឱ្យខ្ចី និង អ្នកខ្ចី តែប៉ុណ្ណោះ ។

**មាត្រា ៥៨០.–** ការដកកិច្ចសន្យាខ្ចីបរិភោគមិនយកការប្រាក់ដែលមិនធ្វើជាលិខិតលាយល័ក្ខណ៍អក្សរ

ចំពោះកិច្ចសន្យាខ្ចីបរិភោគមិនយកការប្រាក់ដែលមិនធ្វើជាលិខិតលាយល័ក្ខណ៍អក្សរ ភាគីនីមួយៗនៃកិច្ចសន្យា អាចដកកិច្ចសន្យានោះនៅពេលណាក៏បាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះផ្នែកនៃវត្ថុដែលជាកម្មវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ហើយ ។

**មាត្រា ៥៨១.–** ការរំលាយដោយការធ្លាក់ចុះនូវទំនុកចិត្តចំពោះអ្នកខ្ចី

១-នៅក្នុងចន្លោះពេលដែលកិច្ចសន្យាបានបង្កើតឡើង រហូតទៅដល់ពេលប្រគល់វត្ថុដែលជាកម្មវត្ថុ ប្រសិនបើស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចី ធ្លាក់ចុះយ៉ាងខ្លាំង ដែលនឹងធ្វើឱ្យមានឧបសគ្គដល់ការអនុវត្តកាតព្វកិច្ចសង អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាខ្ចីបរិភោគបាន ។

២-បើអ្នកឱ្យខ្ចីបានរំលាយកិច្ចសន្យាដោយផ្អែកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នៅក្នុងករណីដែលបានទទួលការប្រាក់កម្រៃជើងសារ ឬ តម្លៃថ្នូរផ្សេងទៀតជាមុន អ្នកឱ្យខ្ចីនោះត្រូវសងទៅឱ្យអ្នកខ្ចីវិញ ។

**មាត្រា ៥៨២.–** ឧបសន្យានៃការខ្ចីបរិភោគ

១-បុគ្គលដែលមានករណីយកិច្ចផ្តល់តាវកាលិកជាប្រាក់ ឬ វត្ថុជំនួសផ្សេងទៀត ដោយមូលហេតុក្រៅអំពីការខ្ចីបរិភោគ ប្រសិនបើបានព្រមព្រៀងជាមួយម្ចាស់បំណុលថា យកវត្ថុនោះធ្វើជាកម្មវត្ថុនៃការខ្ចីបរិភោគ ការខ្ចីបរិភោគត្រូវបានបង្កើតឡើងដោយការព្រមព្រៀងនេះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រាតិភោគ

សម្រាប់កាតព្វកិច្ចចាស់ ត្រូវបានសន្មតថា ត្រូវក្លាយទៅជាប្រាតិភោគសម្រាប់កាតព្វកិច្ចថ្មី ។

## ផ្នែកទី ២
## ការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

**មាត្រា ៥៨៣.–** សិទ្ធិលើបំណុលដែលជាការប្រាក់

១-ការប្រាក់ សំដៅទៅលើចំនួនទឹកប្រាក់ ឬ វត្ថុផ្សេងទៀត ដែលត្រូវបានផ្តល់ទៅឱ្យតាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ ក្នុងនាមជាតម្លៃតបចំពោះការប្រើប្រាស់ប្រាក់ ឬ វត្ថុ ដែលត្រូវបានប្រគល់ឱ្យអ្នកខ្ចី ហើយដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ ឬ វត្ថុ ដែលបានខ្ចី មកគុណជាមួយនឹងអត្រាដែលត្រូវបានកំណត់ ។

២-នៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ វត្ថុដែលត្រូវបានប្រគល់ឱ្យអ្នកខ្ចី ហៅថា ប្រាក់ដើម ភាគដែលបានកំណត់ ដែលត្រូវបានដាក់ចូលទៅក្នុងចំនួនទឹកប្រាក់នៃប្រាក់ដើម ហៅថាអត្រាការប្រាក់ ។

៣-ភាគីនៃកិច្ចសន្យាខ្ចីបរិភោគ អាចយកកម្មវត្ថុនៃការសងការប្រាក់មកបង្កើតជាសិទ្ធិលើបំណុល តាមការព្រមព្រៀងបាន ។ ប៉ុន្តែ ចំពោះការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ ប្រសិនបើពុំបានធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់អ្នកខ្ចីទេ ពុំមានអានុភាពឡើយ ។

៤-នៅក្នុងការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ ដោយមិនយោលតាមលិខិតជាលាយល័ក្ខណ៍អក្សរ ដែលមានចុះហត្ថលេខារបស់អ្នកខ្ចី ប្រសិនបើអ្នកខ្ចីបានសងដោយដឹងអំពីការអនុវត្តបញ្ញត្តិវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ ខាងលើនេះ ការសងមានអានុភាពត្រឹមកម្រិតដែលត្រូវបានសងនោះតែប៉ុណ្ណោះ ។

**មាត្រា ៥៨៤.–** អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និង អត្រាការប្រាក់ក្នុងកិច្ចសន្យា

១-អត្រាការប្រាក់ អាចកំណត់បានតាមបញ្ញត្តិច្បាប់ ឬ ដោយការព្រមព្រៀងរបស់ភាគី ។

២-ក្នុងករណីដែលត្រូវបង់ការប្រាក់ តាមការព្រមព្រៀងរវាងភាគី ឬ បញ្ញត្តិច្បាប់ ប្រសិនបើភាគីពុំបានកំណត់អំពីអត្រាការប្រាក់ទេនោះ ត្រូវអនុលោមតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ដែលបញ្ញត្តនៅក្នុងក្រមនេះ ឬ ច្បាប់ពិសេស ។

៣-អត្រាការប្រាក់ដែលកំណត់តាមការព្រមព្រៀងរបស់ភាគី ហើយដែលហួសអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ពុំមានអានុភាពឡើយ បើពុំបានកំណត់តាមលិខិតជាលាយល័ក្ខណ៍អក្សរ យោងតាមរូបមន្តដែលកំណត់ក្នុងកថាខណ្ឌទី ៣ មាត្រា ៥៨៣ (សិទ្ធិលើបំណុលដែលជាការប្រាក់) ខាងលើទេ ។

**មាត្រា ៥៨៥.-** ការកម្រិតការប្រាក់

១-អត្រាការប្រាក់ដែលត្រូវបានកម្រិត សំដៅទៅលើអត្រាការប្រាក់អតិបរមាដែលអាចកំណត់បានដោយស្របច្បាប់ តាមការព្រមព្រៀងរបស់ភាគី ដែលកំណត់ដោយច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត ។

២-ភាគីអាចកំណត់ការប្រាក់ ខ្ពស់ជាងអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ដែលបានបញ្ញត្តក្នុងកថាខណ្ឌទី ២ នៃមាត្រា ៥៨៤ (អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និង អត្រាការប្រាក់ក្នុងកិច្ចសន្យា) ខាងលើនេះ បាន តែមិនអាចកំណត់លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតបានឡើយ ។

៣-ប្រសិនបើភាគីបានកំណត់អត្រាការប្រាក់លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិត កិច្ចសន្យានៃភាគដែលលើសពីកម្រិតនៃអត្រាការប្រាក់នោះ ត្រូវទុកជាមោឃៈ រីឯអ្នកខ្ចីមានករណីយកិច្ចសងតែចំពោះការប្រាក់ដែលត្រូវបានគណនា តាមអត្រាការប្រាក់ដែលត្រូវបានកម្រិតនោះ តែប៉ុណ្ណោះ ។

៤-នៅក្នុងករណីដែលបានសងការប្រាក់ដែលលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតហើយ ត្រូវចាត់ទុកថាភាគដែលលើសពីការកម្រិតនោះ ជាការកាត់បំណុលទៅលើប្រាក់ដើម ។ នៅក្នុងករណីដែលបានកាត់បំណុលទៅលើប្រាក់ដើម ចំពោះផ្នែកដែលលើសពីការកម្រិតហើយ តែនៅមានសេសសល់ទៀត អ្នកឱ្យខ្ចីត្រូវសងទៅឱ្យអ្នកខ្ចីដោយភ្ជាប់ជាមួយ នូវប្រាក់សំណងនៃការខូចខាត ដោយគណនាតាមអត្រាការប្រាក់ដែល

កំណត់ដោយច្បាប់ ដោយគិតចាប់ពីថ្ងៃដែលបានបង្កើតឱ្យមានការសេសសល់នៃការសង រហូតដល់ថ្ងៃដែលបានសងនោះ ។

៥-ចំពោះការអនុវត្តមាត្រានេះ នៅក្នុងករណីដែលចំនួនប្រាក់ដើមលើកិច្ចសន្យា ខុសគ្នាពីចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ដោយជាក់ស្តែង ដូចជាករណីនៃ ការប្រគល់ប្រាក់ដើមដោយដកការប្រាក់ដែលត្រូវបង់នាពេលអនាគត ជាអាទិ៍ ចំនួន ទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ដោយជាក់ស្តែងទៅឱ្យអ្នកខ្ចីនោះ ត្រូវទុកជាចំនួន ប្រាក់ដើម ។

៦-ចំពោះការអនុវត្តមាត្រានេះ ប្រាក់ និង វត្ថុផ្សេងទៀត ដែលអ្នកឱ្យខ្ចីបានទទួល ក្រៅពីប្រាក់ដើម ទាក់ទងទៅនឹងកិច្ចសន្យាខ្ចីបរិភោគ ទោះបីជាបានទទួលនៅក្នុងនាមជា ប្រាក់រង្វាន់ កម្រៃជើងសារ កម្រៃស៊ើបអង្កេត និង កម្រៃផ្សេងៗទៀតក៏ដោយ ត្រូវចាត់ទុក ថាជាការប្រាក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសោហ៊ុយនៃការធ្វើ កិច្ចសន្យា និង សោហ៊ុយនៃការសង ។

**មាត្រា ៥៨៦.–** ពេលវេលានៃការបង់ការប្រាក់ និង ការប្រាក់សមាសដែលកំណត់ដោយ ច្បាប់

១-បើគ្មានការកំណត់ពិសេសទេ ការប្រាក់ ត្រូវបង់នៅរៀងរាល់ពេលដែលពេល វេលា ១ (មួយ) ឆ្នាំ បានកន្លងផុត គិតចាប់ពីពេលដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ ប្រសិនបើត្រូវសងវត្ថុដែលជាកម្មវត្ថុនោះ នៅមុនពេលដែលពេលវេលា ១ (មួយ) ឆ្នាំ មិនទាន់បានកន្លងផុត ត្រូវបង់ការប្រាក់នៅពេលប្រគល់វត្ថុដែលជាកម្មវត្ថុនោះ ។

២-ក្នុងករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ សម្រាប់រយៈពេលចាប់ ពី ១ (មួយ) ឆ្នាំ ឡើងទៅ ហើយទោះបីជាអ្នកឱ្យខ្ចីបានដាស់តឿនឱ្យសងយ៉ាងណាក៏ដោយ ក៏អ្នកខ្ចីមិនព្រមសងការប្រាក់នោះ អ្នកឱ្យខ្ចីអាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន ។

## ផ្នែកទី ៣
## ករណីយកិច្ចឱ្យខ្ចីរបស់អ្នកឱ្យខ្ចី

**មាត្រា ៥៨៧.–** ករណីយកិច្ចឱ្យខ្ចីវត្ថុដែលជាកម្មវត្ថុ

១-អ្នកឱ្យខ្ចី មានករណីយកិច្ចឱ្យអ្នកខ្ចីប្រើប្រាស់វត្ថុ ដោយសមស្របតាមកិច្ចសន្យា ។

២-អ្នកខ្ចី អាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងវត្ថុ ដោយសេរីបាន ហើយត្រូវទទួលបន្ទុកហានិភ័យ លើការបាត់បង់ ឬ ខូចខាត ចំពោះវត្ថុដែលជាកម្មវត្ថុ ដែលកើតឡើងដោយសារមូលហេតុដែលមិនមែនជាបន្ទុករបស់អ្នកឱ្យខ្ចី ក្នុងនាមជាកម្មសិទ្ធិករ គិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់វត្ថុដែលជាកម្មវត្ថុ ។

**មាត្រា ៥៨៨.–** ការទទួលខុសត្រូវក្នុងការធានា របស់អ្នកឱ្យខ្ចី ក្នុងការប្រគល់វត្ថុរបស់អ្នកដទៃ

១-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ អ្នកឱ្យខ្ចីដែលបានប្រគល់វត្ថុដែលមិនស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន មានករណីយកិច្ចត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិនៃវត្ថុនោះ ហើយផ្ទេរទៅឱ្យអ្នកខ្ចី ឬ ត្រូវប្ដូរជាមួយនឹងវត្ថុផ្សេងទៀតដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន ។ ប៉ុន្តែ នៅក្រោយពេលដែលអ្នកខ្ចីបានបរិភោគវត្ថុនោះរួចហើយ ពុំអាចទាមទារឱ្យប្រគល់វត្ថុជំនួសបានឡើយ ។

២-ប្រសិនបើអ្នកឱ្យខ្ចី ពុំអាចអនុវត្តកាតព្វកិច្ចដែលបានបញ្ញត្តក្នុងកថាខណ្ឌទី ១ ខាងលើនេះទេ អ្នកខ្ចីអាចរំលាយកិច្ចសន្យាបាន ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ប្រសិនបើបានទទួលការប្រគល់ដោយពុំបានដឹងថាអ្នកឱ្យខ្ចីនោះគ្មានសិទ្ធិ អ្នកខ្ចីអាចទាមទារឱ្យអ្នកឱ្យខ្ចីសងសំណងនៃការខូចខាតបាន ។

៤-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដោយគ្មានការប្រាក់ បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតែករណីដែលអ្នកឱ្យខ្ចីបានដឹងថាខ្លួនគ្មានសិទ្ធិចាត់ចែងវត្ថុដែលជាកម្មវត្ថុ ហើយបានប្រគល់វត្ថុរបស់អ្នកដទៃនោះ

ដោយពុំបានជូនដំណឹងទៅឱ្យអ្នកខ្ចី ។

៥-លើកលែងតែករណីដែលបានទទួលការប្រគល់វត្ថុជំនួស ដោយផ្អែកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ៤ ខាងលើនេះ ប្រសិនបើអ្នកខ្ចីវត្ថុរបស់អ្នកដទៃ បានសងវត្ថុដែលត្រូវបានផ្តល់ ឬ តម្លៃនៃវត្ថុនោះ ឱ្យទៅកម្មសិទ្ធិករ អ្នកខ្ចីវត្ថុរបស់អ្នកដទៃនោះ ត្រូវរួចផុតពីករណីយកិច្ចសង ចំពោះអ្នកឱ្យខ្ចី ។

**មាត្រា ៥៨៩.–** សិទ្ធិរំលាយរបស់អ្នកឱ្យខ្ចីវត្ថុអ្នកដទៃ

អ្នកឱ្យខ្ចីដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ ដោយពុំដឹងថាជាវត្ថុរបស់អ្នកដទៃ ប្រសិនបើពុំអាចធ្វើឱ្យអ្នកខ្ចីបានលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុ ឬ វត្ថុជំនួសទេ អាចរំលាយកិច្ចសន្យាបាន ។ ប៉ុន្តែ ប្រសិនបើអ្នកខ្ចីសុចរិត មានសិទ្ធិទាមទារសំណងនៃការខូចខាត ដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៥៨៨ (ការទទួលខុសត្រូវក្នុងការធានា របស់អ្នកឱ្យខ្ចី ក្នុងការប្រគល់វត្ថុរបស់អ្នកដទៃ) ខាងលើនេះ លុះត្រាតែក្នុងករណីដែលបានសងសំណងនៃការខូចខាតនោះ ទើបអាចរំលាយកិច្ចសន្យាបាន ។

**មាត្រា ៥៩០.–** ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឱ្យខ្ចីនូវវត្ថុដែលមានវិការៈ

១-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ប្រសិនបើមានវិការៈកំបាំងនៅក្នុងវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ អ្នកខ្ចីដែលបានទទួលការប្រគល់ដោយមិនបានដឹងអំពីវិការៈនោះ អាចទាមទារឱ្យប្តូរជាមួយនឹងវត្ថុដែលគ្មានវិការៈ និង អាចទាមទារសំណងនៃការខូចខាតបាន ។

២-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលគ្មានការប្រាក់ អ្នកខ្ចីដែលបានទទួលការប្រគល់វត្ថុដែលមានវិការៈ អាចសងតម្លៃនៃវត្ថុដែលមានវិការៈបាន ។ ប៉ុន្តែ បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកឱ្យខ្ចីបាន ដឹងអំពីវិការៈនោះហើយ តែពុំបានជូនដំណឹងទៅឱ្យអ្នកខ្ចី ។

## ផ្នែកទី ៤
## ករណីយកិច្ចសងរបស់អ្នកខ្ចី

**មាត្រា ៥៩១.–** ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី

១-អ្នកខ្ចី មានករណីយកិច្ចត្រូវសងទៅអ្នកឱ្យខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង ។

២-អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ត្រូវបង់ការប្រាក់ តាមបញ្ញត្តិពីមាត្រា ៥៨៤ (អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និង អត្រាការប្រាក់ក្នុងកិច្ចសន្យា) ដល់មាត្រា ៥៨៦ (ពេលវេលានៃការបង់ការប្រាក់ និង ការប្រាក់សមាសដែលកំណត់ដោយច្បាប់) នៃក្រមនេះ ។

**មាត្រា ៥៩២.–** ការសងដោយយោលតាមតម្លៃ

១-ប្រសិនបើពុំអាចសងដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៥៩១ (ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី) ខាងលើបានទេ អ្នកខ្ចីមានករណីយកិច្ចត្រូវបង់ប្រាក់ដែលសមរម្យនឹងតម្លៃនៃវត្ថុដែលជាកម្មវត្ថុ នៅទីកន្លែង និង ថ្ងៃដែលត្រូវសង ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើពុំបានកំណត់ថ្ងៃ ឬ ទីកន្លែងដែលត្រូវសងទេ ត្រូវចាត់ទុកថាត្រូវបង់ចំនួនប្រាក់ដែលសមរម្យនឹងតម្លៃនោះ នៅថ្ងៃ និង ទីកន្លែងដែលបានធ្វើកិច្ចសន្យា ។

**មាត្រា ៥៩៣.–** ការប្រែប្រួលនៃតម្លៃរូបិយវត្ថុ ជាអាទិ៍

ទោះបីជាតម្លៃរូបិយវត្ថុ ឬ តម្លៃនៃវត្ថុ មានការប្រែប្រួល នៅមុនពេលសងក៏ដោយ លើកលែងតែក្នុងករណីដែលមានការព្រមព្រៀងពិសេស អ្នកខ្ចីត្រូវសងនូវចំនួនទឹកប្រាក់ដូចគ្នានឹងចំនួនទឹកប្រាក់ដែលទទួលបានពីការប្រគល់ ។

**មាត្រា ៥៩៤.–** ពេលវេលានៃការសង

១-ប្រសិនបើភាគីបានកំណត់កាលបរិច្ឆេទនៃការសង អ្នកឱ្យខ្ចីមិនអាចទាមទារឱ្យ

មានភ្ជាប់បន្ទុក បុគ្គលនោះអាចទាមទារ ចំពោះភាគីម្ខាងទៀតឱ្យផ្តល់តាវកាលិកបាន ។

៤-នៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក បើគ្មានកិច្ចសន្យាពិសេសទេ លុះត្រាតែភាគីម្ខាងមិនបានធ្វើការផ្តល់តាវកាលិកទេ ទើបភាគីម្ខាងទៀតនៃកិច្ចសន្យា អាចមិនផ្តល់តាវកាលិករបស់ខ្លួនបាន ។

៥-ទាយកនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក អាចរំលាយកិច្ចសន្យាប្រទានកម្មដែលមានភ្ជាប់បន្ទុកនោះ តាមបញ្ញត្តិនៃការរំលាយកិច្ចសន្យាបាន នៅក្នុងករណីដែលភាគីម្ខាងទៀតមិនបានអនុវត្តបន្ទុក ។

**មាត្រា ៥៧៧.–** ប្រទានកម្មដោយមូលហេតុមរណភាព

១-ប្រទានកម្មដែលបង្កើតអានុភាពដោយមរណភាពរបស់ទាយក ត្រូវហៅថាប្រទានកម្មដោយមូលហេតុមរណភាព ។

២-បញ្ញត្តិនៃអច្ច័យទាន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃប្រទានកម្មដោយមូលហេតុមរណភាព ។

## ជំពូកទី ៤
## ការខ្ចីបរិភោគ

### ផ្នែកទី ១
### និយមន័យ និង ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

**មាត្រា ៥៧៨.–** និយមន័យនៃការខ្ចីបរិភោគ

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ឬ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពី

# ឧបសម្ព័ន្ធទី២

# ច្បាប់

# ស្តីពី

# ការអនុវត្តក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/០៥១១/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ចូល លេខ... ថ្ងៃទី... ឆ្នាំ២០១១ ម៉ោង... បញ្ជូនទៅ...

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលរដ្ឋសភា បានអនុម័ត កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្ដីពី

# ការអនុវត្តក្រមរដ្ឋប្បវេណី

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១៧.- អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍**

១-អត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រឹមអត្រាចាប់ពី ១០ (ដប់) ភាគរយទៅ ៣០ (សាមសិប) ភាគរយក្នុង ១ (មួយ) ឆ្នាំ ។

២-ចំពោះការព្រមព្រៀងអំពីការកំណត់ជាមុននូវចំនួននៃសំណង ក្នុងករណីមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ប្រសិនបើផលចែកនៃចំនួនប្រាក់សំណងការខូចខាតដែលបានកំណត់មុន នោះជាមួយនឹងប្រាក់ដើម លើសពីអត្រាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ភាគដែលលើសនោះត្រូវទុកជាមោឃៈ ។

៣-ប្រកាសខាងលើអាចកំណត់អត្រាដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើបាន ត្រឹមទំហំពី ១,២ ទៅ ២ ដង នៃអត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

៤-កថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ នៃមាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីកូនបំណុលដែលបានបង់ផ្នែកលើស ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៤ ខាងលើ ត្រូវអនុវត្តចំពោះប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ដោយចាត់ទុកថា ប្រាក់ធានានោះជាការកំណត់ជាមុននូវចំនួននៃសំណងក្នុងកម្រិតនៃការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៤ ខាងលើនេះ ។

៦-ក្នុងករណីមិនមានការសន្យាពិសេសណាមួយស្ដីពីប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ដែលភ្ជាប់ជាមួយនឹងការប្រាក់ បញ្ញត្តិនៃមាត្រានេះ និង មាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវអនុវត្តចំពោះប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវ ដោយចាត់ទុកថា ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវនោះជាការប្រាក់ ក្នុងកម្រិតនៃការអនុវត្តបញ្ញត្តិនៃមាត្រានេះ និង មាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណីនោះ ។

# ឧបសម្ព័ន្ធទី៣

## ក្រឹត្យ~ច្បាប់
## ស្តីពី
## កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា

# ក្រឹត្យ-ច្បាប់

## ស្តីពី

## កិច្ចសន្យា និងការទទួល
## ខុសត្រូវក្រៅកិច្ចសន្យា

**សាធារណរដ្ឋប្រជាមានិតកម្ពុជា**

**ឯករាជ សន្តិភាព សេរីភាព សុភមង្គល**

********

ក្រុមប្រឹក្សារដ្ឋ

\-\-\-\-\-\-\-\-\-

លេខ ៣៨ ក្រ.ច

ក្រឹត្យ-ច្បាប់

ស្តីអំពី

កិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា

ក្រុមប្រឹក្សារដ្ឋ

នៃ

សាធារណៈរដ្ឋមានិតកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់នៃការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃសាធារដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២.
- បានឃើញច្បាប់នៃអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២.
- បានឃើញច្បាប់ស្តីពីការចាត់តាំងតុលាការ និងអយ្យការ ដលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០២ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២ ។
- បានឃើញច្បាប់ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និង មហាអយ្យការអមតុលាការប្រជាជនកំពូល ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៨៥
- បានឃើញក្រឹត្យ-ច្បាប់ លេខ ៣៤ ក្រ ច ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៨៧ ស្តីពីការចាត់តាំង និងសកម្មភាពរបស់តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល
- បានឃើញក្រឹត្យ-ច្បាប់ លេខ ០៧ ក្រ ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា
- តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

**សំរេច**

.......

# ជំពូកទី១

## ស្តីអំពីកិច្ចសន្យា

### ផ្នែកទី១ បទបញ្ញត្តិទូទៅ

**មាត្រា១-** កិច្ចសន្យា គឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គល២នាក់ ឬ ច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬ ច្រើនដែលទាក់ទិននិងខ្លួន ។

ក្នុងអត្ថន័យខាងលើ បុគ្គលអាចជារូបវន្តបុគ្គល ជានីតិបុគ្គល ។

នីតិបុគ្គល អាចធ្វើកិច្ចសន្យាតាមរយៈបុគ្គលដែលជាតំណាងរបស់ខ្លួន ។

**មាត្រា២-** កិច្ចសន្យាទាំងឡាយ ត្រូវរួមចំណែកក្នុងការផ្សារភ្ជាប់ផលប្រយោជន៍បុគ្គល និងផលប្រយោជន៍សង្គម ។

ភាគីនៃកិច្ចសន្យា ត្រូវសហការនិងគ្នាក្នុងបរិយាកាសទុកចិត្ត ស្មោះត្រង់និងគ្នា អនុវត្តសមស្របនិងគោល-ការណ៍សីលធម៌សង្គម ហើយជាពិសេស កំចាត់នូវគំនិត មនុស្សជិះជាន់មនុស្ស ។

### ផ្នែកទី២ សុពលភាព និងទំរង់នៃកិច្ចសន្យា

**មាត្រា៣-** កិច្ចសន្យាទាំងឡាយនិងយកជាការបាន លុះណាតែការតព្វកិច្ចដែលកើតពីកិច្ចសន្យានោះ :

១. កើតចេញពីការព្រមព្រៀងដោយពិតប្រាកដ និង ដោយសេរី

២. កើតចេញពីជនដែលមានសមត្ថភាពចុះកិច្ចសន្យា

៣. មានវត្ថុមួយដែលជាក់លាក់ ដែលអាចធ្វើកើត និងដែលស្របច្បាប់របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ ។

**មាត្រា៤-** កិច្ចសន្យាអាចធ្វើដោយផ្ទាល់មាត់ ឬ ជាលាយល័ក្ខអក្សរ ។ ច្បាប់អាចកំណត់ឱ្យមានទំរង់មួយជាក់លាក់ក្នុងការធ្វើកិច្ចសន្យា ។ កិច្ចសន្យាទាំងឡាយណា ដែលមិនបានធ្វើតាមទំរង់ដែលច្បាប់បានកំណត់ត្រូវទុកជាមោឃៈ លើកលែងតែមានបទបញ្ញត្តិនៃវិធានច្បាប់ណាមួយកំនត់ផ្ទុយពីនេះ ។

កិច្ចសន្យាគ្រប់ប្រភេទ ស្តីពីប្រាក់ ឬវត្ថុដែលមានចំនួន ឬមានតំលៃលើសពីប្រាំពាន់រៀល ត្រូវធ្វើជាលាយ-លក្ខអក្សរ ។

### ផ្នែកទី៣ មោឃៈភាពនៃកិច្ចសន្យា

**មាត្រា៥-** ត្រូវទុកជាមោឃៈជាដាច់ខាត :

# ឧបសម្ព័ន្ធទី៣

# ប្រកាស

# ស្តីពី

# អត្រាការប្រាក់ដែលត្រូវបានកម្រិត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ១២៨ ភ.យ.ប.ក/១១

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែ ៦ ឆ្នាំ ២០១១

# ប្រកាស

## ស្តីពី

## អត្រាការប្រាក់ដែលត្រូវបានកម្រិត

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

### សម្រេច

**ប្រការ ១.-**

អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុង ១ (មួយ) ឆ្នាំ។

**ប្រការ ២.-**

អត្រាការប្រាក់ ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវ

បានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពីចំនួន ១,៥ (មួយក្បៀសប្រាំ) ដង នៃអត្រាការប្រាក់ដែលបានកំណត់ក្នុងប្រការ ១ ខាងលើ។

<u>ប្រការ ៣</u>.-

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនា

<u>ចម្លងជូន៖</u>

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -តុលាការ និងមហាអយ្យការ -អយ្យការអមតុលាការគ្រប់ជាន់ថ្នាក់
- -ឯកសារ-កាលប្បវត្តិ។